



# សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្ដែងសម្រាប់ការងាររប
# ស់អ្នកជំនួយការងារផ្ទះដែលបានមកពីបរទេស

## *អ្វីដែលអ្នកជំនួយការងារផ្ទះដែលបានមកពីបរទេស និងនិយោជករបស់គាត់គួរយល់ដឹង*

*Practical Guide For Employment of Foreign Domestic Helpers*
*What foreign domestic helpers and their employers should know*



Khmer Version 柬埔寨文版本

Labour Department

# មាតិកា


| | | |
|---|---|---|
| អារម្ភកថា | | 1 |
| ជំពូកទី ១ | ការងារដំបូង | 2 |
| ជំពូកទី ២ | សំណងលើថ្លៃធ្វើឯកសារ | 7 |
| ជំពូកទី ៣ | ការចំណាយ និងការកាត់ប្រាក់ឈ្នួល | 9 |
| ជំពូកទី ៤ | ថ្ងៃឈប់សម្រាកធម្មតា ថ្ងៃឈប់សម្រាកបុណ្យជាតិ និងច្បាប់ឈប់សម្រាក | 12 |
| ជំពូកទី ៥ | របបថែទាំសុខភាព និងប្រាក់ឧបត្ថម្ភនៅពេលមានជម្ងឺ | 17 |
| ជំពូកទី ៦ | ការគាំពារនៅពេលសម្រាកមាតុភាព | 19 |
| ជំពូកទី ៧ | ច្បាប់ឈប់សម្រាកបិតុភាព | 21 |
| ជំពូកទី ៨ | ការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ | 23 |
| ជំពូកទី ៩ | ប្រាក់ដែលផ្តល់ឱ្យក្រោយឈប់ធ្វើការ និងប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះដោយជំនួសការមិនបានបន្តកិច្ចសន្យា | 27 |
| ជំពូកទី ១០ | ការគាំពារការងារ | 29 |
| ជំពូកទី ១១ | ការត្រឡប់មកមាតុភូមិវិញដោយឥតគិតថ្លៃ ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុក និងការធ្វើដំណើរ | 31 |
| ជំពូកទី ១២ | សំណួរ និងបណ្តឹង | 32 |
| ឧបសម្ព័ន្ធទី I | កិច្ចសន្យាការងារ (សម្រាប់អ្នកជួយធ្វើការផ្ទះដែលបានជ្រើសរើសពីបរទេស) (គំរូសម្រាប់ជាឯកសារយោង) | 34 |
| ឧបសម្ព័ន្ធទី II | គំរូនៃវិក័យបត្រសម្រាប់សំណងលើថ្លៃរត់ ឬរៀបចំឯកសារ | 41 |
| ឧបសម្ព័ន្ធទី IIIក | - គំរូនៃវិក័យបត្រប្រាក់ឈ្នួលផ្តល់ឱ្យអ្នកជំនួយការងារផ្ទះដែលបានមកពីបរទេស | 42 |
| ឧបសម្ព័ន្ធទី IIIខ | - កំណត់ត្រាច្បាប់ឈប់សម្រាករបស់អ្នកជំនួយការងារផ្ទះមកពីបរទេស | 43 |
| ឧបសម្ព័ន្ធទី IVក | - គំរូលិខិតបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ដោយអ្នកជំនួយការងារផ្ទះមកពីបរទេស | 45 |
| ឧបសម្ព័ន្ធទី IVខ | - គំរូលិខិតបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ដោយនិយោជករបស់អ្នកជំនួយការងារផ្ទះដែលបានមកពីបរទេស | 46 |
| ឧបសម្ព័ន្ធទី V | គំរូនៃវិក័យបត្រសម្រាប់ការចំណាយនៅពេលបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ / តាមកាលកំណត់ | 47 |
| ឧបសម្ព័ន្ធទី VI | សំណួរ | 48 |

# អារម្ភកថា

សៀវភៅណែនាំនេះមានគោលបំណងក្នុងការផ្តល់ជំនួយជាឯកសារយោង ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់និយោជក និងអ្នកជំនួយការងារផ្ទះ ដែលទាក់ទងនឹងការងាររបស់អ្នកជំនួយការងារផ្ទះមកពីបរទេសធ្វើការនៅហុងកុង ។ គោលបំណងនៃសៀវភៅនេះឆ្លើយតបនឹងចម្ងល់មួយចំនួន ដែលលើកឡើងដោយអ្នកជំនួយការងារផ្ទះពីបរទេស និងនិយោជករបស់ពួកគាត់ ។

អ្នកជំនួយការងារផ្ទះពីបរទេស មានសិទ្ធិ និងទទួលបានអត្ថប្រយោជន៍ និងការគាំពារដូចគ្នា យោងតាមបទប្បញ្ញត្តិការងារ ។ ចំពោះព័ត៌មានលម្អិតស្តីពីលក្ខខ័ណ្ឌការងារ និងបទប្បញ្ញត្តិច្បាប់ និយោជក និងអ្នកជំនួយការងារផ្ទះពីបរទេស គួរស្វែងយល់បន្ថែមដែលមាននៅក្នុងកិច្ចសន្យាការងារស្តង់ដារ (អត្តលេខ ID 407) និងបទប្បញ្ញតិការងារ ដែលរក្សាទុកនៅអាជ្ញាធរតែមួយគត់ សម្រាប់ការពន្យល់បទប្បញ្ញត្តិទាំងនេះ ។ តុលាការគឺមានសិទ្ធិបកស្រាយច្បាប់ ដែលឆ្លើយតបទៅនឹងសំណួរនានា ។

# ១ ការងារដំបូង

## សម្រាប់ទាំងនិយោជក និងស្ត្រីជំនួយការផ្ទះ

**ស១.១ តើអ្វីទៅជាសិទ្ធិ និងការទទួលខុសត្រូវទាក់ទងនឹងការងាររបស់ខ្ញុំក្នុងនាមជាអ្នកជំនួយការងារផ្ទះមកពីបរទេស ឬជានិយោជករបស់អ្នកជំនួយការងារផ្ទះមកពីបរទេស?**

**ច** សិទ្ធិ និងការទទួលខុសត្រូវជាមូលដ្ឋាន ទាក់ទងនឹងការងាររបស់អ្នកជំនួយការងារផ្ទះមកពីបរទេស គឺបានបញ្ជាក់ នៅក្នុងកិច្ចសន្យាការងារស្តង់ដារ (អត្តលេខ ID ៤០៧) (ឧបសម្ព័ន្ធទី I) ។ បន្ថែមលើនេះ បទប្បញ្ញត្តិការងារក៏បានបញ្ជាក់ពីសិទ្ធិ និងការទទួលខុសត្រូវចំពោះនិយោជក និងអ្នកជំនួយការងារផ្ទះ ផងដែរ ។

**ស១.២ តើនឹងមានការដាក់ទណ្ឌកម្មទៅលើអ្នកជំនួយការងារផ្ទះ និងនិយោជិកដែរឬទេ ប្រសិនបើពួកគេរំលោភបំពានលើលក្ខខណ្ឌ ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាការងារស្តង់ដារ?**

**ច** (សូមអានសំណួរ និងចម្លើយទី ១.១, ១.៤, ១.៥, ១.៨, និង១.៩ នៃសៀវភៅណែនាំនេះ)

- ទាំងអ្នកជំនួយការងារផ្ទះ និងនិយោជកត្រូវអនុវត្តទៅតាមរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង ដូចមានចែងនៅផ្នែកទី៦ នៃ"ទម្រង់ពាក្យស្នើសុំទិដ្ឋាការ ឬពន្យាការស្នាក់នៅរបស់អ្នកជំនួយការងារផ្ទះមកពីបរទេស" (ID 988A) និង "ពាក្យស្នើសុំធ្វើការងាររបស់អ្នកជំនួយការងារផ្ទះមកពីបរទេស" (ID 988B) ដែលពួកគេត្រូវតែពិនិត្យមើលឱ្យបានម៉ត់ចត់ ដូចជា៖ លក្ខខណ្ឌនានារបស់ជំនួយការតាមផ្ទះ ក៏ដូចជាកម្រិតប្រាក់ឈ្នួល ការរស់នៅ និងតម្រូវការសម្រាប់ការរស់នៅ ។
- ប្រសិនបើអ្នកជំនួយការងារផ្ទះប្រព្រឹត្តបទល្មើសខុស នាងអាចប្រឈមនឹងការមិនអនុញ្ញាតឱ្យធ្វើការនៅហុងកុងម្តងទៀត ។ ប្រសិនបើនិយោជកប្រព្រឹត្តបទល្មើសខុស ពាក្យស្នើសុំរបស់គាត់ ឬនាងក្នុងការយកអ្នកជំនួយការងារផ្ទះនាពេលអនាគតក៏អាចត្រូវច្រានចោលមិនយល់ស្របផងដែរ ។
- និយោជកមិនត្រូវស្តាប់ការញុះញង់ ដើម្បីសរសេរ ឬផ្តល់ព័ត៌មានក្លែងក្លាយក្នុងពាក្យសុំ និងកិច្ចសន្យាការងារស្តង់ដារ ដែលទាក់ទងទៅនឹងការងារនៃអ្នកជំនួយការងារផ្ទះមកពីបរទេស ឬរួមគំនិតជាមួយបុគ្គលណាមួយក្នុងការបោកប្រាស់ដោយចេតនា ដើម្បីយកអ្នកជំនួយការងារផ្ទះមកពីបរទេសឱ្យធ្វើការ ដោយផ្តល់ប្រាក់ឈ្នួលតិចជាងការកំណត់នៅក្នុងកិច្ចសន្យាការងារស្តង់ដារ ។

ប្រសិនបើនិយោជកផ្តល់ព័ត៌មានក្លែងក្លាយទៅនាយកដ្ឋានអន្តោប្រវេសន៍
អំពីប្រាក់ឈ្នួលដែលផ្តល់ឱ្យអ្នកជំនួយការងារផ្ទះមកពី បរទេស
នោះនិយោជកនឹងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលបួនខែ
និងត្រូវផ្តល់ប្រាក់ឈ្នួលទៅឱ្យអ្នកជំនួយការងារផ្ទះឱ្យបានគ្រប់ចំនួន ។
និយោជកត្រូវបានណែនាំឱ្យគោរពតាមច្បាប់ និងត្រូវផ្តល់ប្រាក់ឈ្នួលគ្រប់ចំនួនដល់អ្នកជំនួយការងារផ្ទះ ដូចដែលបានចែងនៅក្នុងកិច្ចសន្យាការងារស្តង់ដារ ។ បើមិនដូច្នោះទេ វានឹងត្រូវបានចាត់ទុកជាបទល្មើស ហើយនិយោជកត្រូវទទួលការកាត់ទោស ។

- បន្ថែមពីនេះ ប្រសិនបើនិយោជក ឬអ្នកជំនួយការងារផ្ទះប្រព្រឹត្តផ្ទុយខុសពីច្បាប់បទប្បញ្ញត្តិការងារ ឬច្បាប់បទប្បញ្ញត្តិអន្តោប្រវេសន៍ គាត់នឹងត្រូវទទួលការកាត់ទោសផ្នែកព្រហ្មទណ្ឌ ។

## សម្រាប់និយោជក

**ស១.៣ តើខ្ញុំគួរធ្វើដូចម្តេច ដើម្បីឱ្យអ្នកជំនួយការងារផ្ទះអាចចាប់ផ្តើមការងារ នៅពេលគាត់បានធ្វើដំណើរមកដល់ ?**

**ច**

- អ្នកគួរតែផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុកជាប្រចាំ និងថ្លៃធ្វើដំណើរ ដល់អ្នកជំនួយការងារផ្ទះ ១០០ ដុល្លារហុងកុងក្នុងមួយថ្ងៃ ដូចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាការងារសម្រាប់ការធ្វើដំណើររបស់គាត់ទៅហុងកុង ។ អ្នកក៏គួរតែជួយសង គាត់ / នាងទៅលើថ្លៃរៀបចំឯកសារសំខាន់ៗទាំងអស់ផងដែរ ។ មើលជំពូកទី២ ។
- អ្នកត្រូវបានណែនាំ សម្រាប់ពន្យល់អ្នកជំនួយការងារផ្ទះរបស់អ្នក ដែលអ្នករំពឹងថា គាត់ / នាងធ្វើការទៅតាមតួនាទីភារកិច្ច ។ តួនាទីភារកិច្ចរបស់គាត់ / នាងត្រូវតែជាតួនាទីភារកិច្ចតែការងារផ្ទះដូចដែលបានបញ្ជាក់ក្នុង "កាលវិភាគនៃការស្នាក់នៅ និងតួនាទីភារកិច្ចការងារផ្ទះ"* នៃកិច្ចសន្យាការងារ ។
- អ្នកគួរតែកំណត់កាលបរិច្ឆេទមួយ ដែលអ្នកនឹងផ្តល់ប្រាក់ឈ្នួលទៅឱ្យអ្នកជំនួយការងារផ្ទះរបស់អ្នក ។ មើលជំពូកទី ៣ ។
- អ្នកគួរតែជ្រើសរើសថ្ងៃឈប់សម្រាកសម្រាប់អ្នកជំនួយការងារផ្ទះរបស់អ្នក ។ មើលជំពូកទី ៤ ។
- អ្នកគួរតែធ្វើការព្រមព្រៀងជាមួយអ្នកជំនួយការងារផ្ទះរបស់អ្នកជាមុនសិន ថាតើការហូបចុកនឹងត្រូវផ្តល់ ឬក៏អត់អំឡុងពេលធ្វើការ ។ ប្រសិនបើអ្នកផ្តល់ការហូបចុកដល់អ្នកជំនួយការងារផ្ទះ នោះត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ។ ប្រសិនបើអ្នកមិនបានផ្តល់ការហូបចុកនោះទេ អ្នកត្រូវឧបត្ថម្ភជាប្រាក់សម្រាប់ការហូបចុកដល់អ្នកជំនួយការងារផ្ទះរបស់អ្នកជំនួសវិញ ដោយបញ្ជាក់ចំនួនទឹកប្រាក់នៅក្នុងកិច្ចសន្យាការងារ សម្រាប់ផ្តល់ឱ្យអ្នកជំនួយការងារផ្ទះក្នុងខែនីមួយៗ ។
- អ្នកគួរតែផ្តល់នូវថ្លៃធានារ៉ាប់រងសងជម្ងឺចិត្តដល់អ្នកជំនួយការងារផ្ទះរបស់អ្នក ជំនួសឱ្យថ្លៃសំណងនៅពេលអ្នកជំនួយការងារផ្ទះទទួលរងរបួសពេលធ្វើការ ដោយវាគឺជាលក្ខខណ្ឌ ឬកាតព្វកិច្ច យោងទៅតាមច្បាប់បទប្បញ្ញត្តិសម្រាប់ថ្លៃជម្ងឺចិត្តដល់បុគ្គលិក ។

ប្រសិនបើអ្នកមិនអនុវត្តតាមបទប្បញ្ញត្តិនេះទេ នឹងត្រូវបានចាត់ជាការប្រព្រឹត្តបទល្មើសផ្ទុយពីច្បាប់ដោយផ្តន្ទាទោសជាការផាកពិន័យ និងជាប់ពន្ធនាគារ ។ ក្រៅពីនេះ អ្នកត្រូវផ្តល់នូវរបបថែទាំសុខភាពដោយឥតគិតថ្លៃដល់អ្នកជំនួយការងារផ្ទះ យោងទៅតាមកិច្ចសន្យាការងារស្តង់ដារ ដូចនេះអ្នកគួរតែយល់ និងអនុវត្តទៅតាមគោលនយោបាយធានារ៉ាប់រងដើម្បីដឹងរាល់ការចំណាយដែលពាក់ព័ន្ធនៅពេលការចំណាយកើនឡើង ។ មើលជំពូកទី ៥ ។

**សវ១.៤ តើខ្ញុំអាចអនុវត្ត និងដាក់កិច្ចសន្យាការងារផ្សេងទៀតឱ្យមានសុពលភាពជាមួយអ្នកជំនួយការងារផ្ទះរបស់ខ្ញុំបានដែរឬទេ?**

**ច** មិនបានទេ ។ កិច្ចសន្យាការងារស្តង់ដារ (ID 407) គឺជាកិច្ចសន្យាការងារស្តង់ដារផ្លូវការដែលធ្វើឡើងតែមួយសម្រាប់អ្នកជំនួយការងារផ្ទះទាំងអស់នៅក្នុងហុងកុង ។ កិច្ចសន្យាការងារផ្សេងទៀតដែលបានដាក់ឱ្យមានសុពលភាពរវាងនិយោជក និងអ្នកជំនួយការងារផ្ទះគឺមិនអាចចាត់ជាធរមានសម្រាប់អនុវត្តក្នុងហុងកុងនោះឡើយ ។

**សវ១.៥ តើខ្ញុំអាចស្នើឱ្យអ្នកជំនួយការងារផ្ទះ របស់ខ្ញុំធ្វើការឱ្យបុគ្គលម្នាក់ផ្សេងទៀត ឬធ្វើការផ្សេងក្រៅពីការងារផ្ទះបានដែរឬទេ?**

**ច** មិនបានទេ ។ យោងទៅតាមបទប្បញ្ញត្តិអន្តោប្រវេសន៍ វានឹងចាត់ជាការប្រព្រឹត្តបទល្មើស ដែលស្នើឱ្យអ្នកជំនួយការងារផ្ទះធ្វើការឱ្យបុគ្គលម្នាក់ផ្សេងទៀត ក្រៅពីនិយោជកដែលមានឈ្មោះនៅក្នុងទិដ្ឋាការរបស់ គាត់ / នាង ឬស្នើឱ្យ គាត់ / នាង ធ្វើការផ្សេងពីការងារផ្ទះ ។ និយោជកអាចប្រឈមមុខនឹងការកាត់ទោស ប្រសិនជារកឃើញថាបានប្រព្រឹត្តបទល្មើសផ្ទុយពីបទប្បញ្ញត្តិអន្តោប្រវេសន៍ ។

## សម្រាប់អ្នកជំនួយការងារផ្ទះ

**សវ១.៦ តើខ្ញុំគួរធ្វើអ្វីខ្លះពេលខ្ញុំចាប់ផ្តើមធ្វើការឱ្យនិយោជករបស់ខ្ញុំ?**

**ច**

- ដើម្បីជួយសម្រួលដល់និយោជករបស់អ្នក ក្នុងការទូទាត់ថ្លៃចំណាយលើឯកសារ អ្នកគួរតែធ្វើវិក្កយបត្រនៃការចំណាយពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំឯកសារ ។
- អ្នកគួរតែស្នើសុំឱ្យនិយោជករបស់អ្នក ពន្យល់អំពីកាតព្វកិច្ចរបស់អ្នក និងយល់ឱ្យបានច្បាស់ពីអ្វីដែលនិយោជកចង់បានពីអ្នកក្នុងការធ្វើការ ។ អ្នកនឹងធ្វើការងារផ្ទះដូចដែលបានបញ្ជាក់ក្នុង "កាលវិភាគនៃការស្នាក់នៅ និងភារកិច្ចការងារផ្ទះ"* នៃកិច្ចសន្យាការងាររបស់អ្នក ។
- អ្នកគួរតែរក្សាឯកសារសម្គាល់ផ្ទាល់ខ្លួន (ឧទាហរណ៍ អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ជាដើម) ។ បុគ្គលណាម្នាក់ រួមទាំងនិយោជករបស់អ្នក ឬបុគ្គលិកនៃទីភ្នាក់ងារជ្រើសរើសគ្មានសិទ្ធិរក្សាទុកឯកសាររបស់អ្នកដោយគ្មានការយល់ស្របពីអ្នកឡើយ ។

**សទ១.៧ តើខ្ញុំអាចរស់នៅក្រៅពីផ្ទះនិយោជករបស់ខ្ញុំបានដែរឬទេ?**

**ច** មិនបានទេ ។ អ្នកគួរតែធ្វើការ និងរស់នៅក្នុងលំនៅដ្ឋានរបស់និយោជករបស់អ្នកដោយអនុលោមតាមកថាខណ្ឌទី៣ នៃកិច្ចសន្យាការងារស្តង់ដារ ។ និយោជករបស់អ្នកគឺត្រូវ ផ្តល់ការស្នាក់នៅឥតគិតថ្លៃដល់អ្នក ដូចដែលបានបញ្ជាក់ក្នុង "កាលវិភាគនៃការស្នាក់នៅ និងភារកិច្ចការងារផ្ទះ"* នៃកិច្ចសន្យាការងារ ។

*(សម្រាប់អ្នកដែលបានទទួលការរៀបចំឱ្យរស់នៅទាំងអស់ ដែលបានអនុម័ត និងយល់ស្របដោយប្រធានផ្នែកអន្តោប្រវេសន៍ មុនថ្ងៃទី១ ខែមេសា ឆ្នាំ២០០៣ អ្នកទាំងនោះក្នុងនាមជាអ្នកជំនួយការងារផ្ទះ ត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងកន្លែងផ្សេងក្រៅពីលំនៅដ្ឋានរបស់និយោជកដែលបានផ្តល់ឱ្យ ហើយនិយោជកនៅតែបន្តទៅជួលអ្នកជំនួយការងារផ្ទះមកពីបរទេសដោយមានការសម្រាកមិនឱ្យច្រើនជាង៦ខែ ។)*

**សទ១.៨ តើខ្ញុំអាចធ្វើការងារផ្សេងក្រៅម៉ោង ដោយមានការយល់ព្រមពីនិយោជករបស់ខ្ញុំបានដែរឬទេ?**

**ច** មិនបានទេ ។ យោងទៅតាមបទប្បញ្ញត្តិអន្តោប្រវេសន៍ វានឹងចាត់ជាបទល្មើស ដែលអ្នកបានធ្វើការជាមួយនឹងបុគ្គលម្នាក់ផ្សេងទៀត ក្រៅពីនិយោជករបស់អ្នកដែលមានឈ្មោះនៅក្នុងទិដ្ឋាការរបស់អ្នក ។ អ្នកនឹងត្រូវទទួលខុសត្រូវទៅតាមការកាត់ទោស និងត្រូវបានបញ្ជូនចេញទាក់ទង ការប្រព្រឹត្តបទល្មើសផ្ទុយពីលក្ខខណ្ឌនៃការស្នាក់នៅ ។ ប្រសិនបើអ្នកត្រូវបានបញ្ជូនចេញ នោះអ្នកនឹងគ្មានសិទ្ធិទទួលបានការអនុញ្ញាត ឱ្យត្រលប់មកធ្វើការជាអ្នកជំនួយការងារផ្ទះនៅហុងកុងម្តងទៀតបានឡើយ ។

**សទ១.៩ តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើនិយោជករបស់ខ្ញុំបញ្ជូនខ្ញុំឱ្យទៅធ្វើការជាមួយបុគ្គលម្នាក់ផ្សេងទៀត ឬធ្វើការដែលមិនមែនជាការងារផ្ទះ?**

**ច** អ្នកគួរតែរាយការណ៍អំពីបញ្ហានេះទៅកាន់ផ្នែកស៊ើបអង្កេតនៃនាយកដ្ឋានអន្តោប្រវេសន៍ ។

* នៅក្នុងកិច្ចសន្យាការងារស្តង់ដារមាន "កាលវិភាគនៃការស្នាក់នៅ និងភារកិច្ចការងារផ្ទះ" ដែលបានបញ្ជាក់ស្តង់ដានៃការស្នាក់នៅ និងសេចក្តីលម្អិតនៃភារកិច្ចការងារផ្ទះដែលអ្នកជំនួយការងារផ្ទះធ្វើ ។

## សខ.១០ តើខ្ញុំគួរដឹងពីអ្វីខ្លះ ក្នុងការការពារសុវត្ថិភាព និងសិទ្ធិរបស់ខ្ញុំ នៅពេលកំពុងធ្វើការនៅហុងកុង?

ច

- ប្រសិនបើអ្នកត្រូវបានគេរំលោភបំពានលើរាងកាយ ឬទទួលរងហានិភ័យទាក់ទងទៅនឹងសុវត្ថិភាពផ្ទាល់ខ្លួន សូមរកជំនួយដោយទូរស័ព្ទភ្លាមៗទៅកាន់បណ្តាញទាន់ហេតុការណ៍របស់ប៉ូលីស "999" ។
- ប្រសិនបើអ្នកមិនបានទទួលប្រាក់ឈ្នួល ឬសិទ្ធិការងារណាមួយរបស់អ្នកត្រូវបានរំលោភបំពាន សូមទូរស័ព្ទទៅកាន់នាយកដ្ឋានការងារ តាមបណ្តាញលេខ "2157 9537" ពេញ២៤ម៉ោង ឬទំនាក់ទំនងផ្ទាល់នៅសាខាការិយាល័យផ្នែកទំនាក់ទំនងនៃនាយកដ្ឋានការងារដើម្បីសាកសួរ និងសុំជំនួយ (សូមមើលជំពូកទី ៣ និង១២) ។
- រក្សាទុកលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណហុងកុងរបស់អ្នកជានិច្ច ។ គ្មានបុគ្គលណាម្នាក់មានសិទ្ធិរក្សាទុកលិខិតឆ្លងដែនរបស់អ្នកនោះទេ ។
- អ្នកមិនគួរចុះហត្ថលេខាលើឯកសារណាមួយដែលអ្នកមិនយល់ ឬមិនយល់ស្របជាមួយ ។

# ២ សំណងលើថ្លៃធ្វើឯកសារ

## សម្រាប់និយោជក

### សខ២.១ តើខ្ញុំត្រូវចំណាយអ្វីខ្លះ លើការសងជំនួសឱ្យអ្នកជំនួយការងារផ្ទះរបស់ខ្ញុំ ទៅតាមកិច្ចសន្យាការងារ?

**ច**

- យោងតាមកិច្ចសន្យាការងារ អ្នកគឺជាអ្នកទទួលខុសត្រូវចំពោះការចំណាយរបស់អ្នកជំនួយការងារផ្ទះអ្នក ក្នុងការរៀបចំឯកសារសម្រាប់ធ្វើការជាមួយអ្នក ។ ជាទូទៅ អ្នកជំនួយការងារផ្ទះបានចំណាយលើថ្លៃទាំងនោះ ហើយអ្នកគួរតែសងមក គាត់ / នាង វិញបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេល គាត់/នាង ផ្តល់វិក្កយបត្រឱ្យ ។ អ្នកគួរតែស្នើសុំឱ្យគាត់/នាង ទទួលស្គាល់លើថ្លៃដែលអ្នកបានសងជំនួសឱ្យជាលាយលក្ខណ៍អក្សរ និងរក្សាបង្កាន់ដៃសម្រាប់ទុកជាភស្តុតាងនៃការទូទាត់ចំណាយនេះ ។
- ដោយយកអ្នកជំនួយការងារផ្ទះមកពីប្រទេសហ្វីលីពីនជាឧទាហរណ៍ អ្នកអាចនឹងត្រូវបង់ដូចខាងក្រោម ៖
  - ថ្លៃសេវារដ្ឋបាលប្រទេសហ្វីលីពីនសម្រាប់ការងារនៅបរទេស (POEA) (ប្រមូលដោយរដ្ឋាភិបាលហ្វីលីពីនសម្រាប់ដំណើរការអនុញ្ញាតក្នុងការចេញដំណើរ និងតម្រូវការវត្តមានរបស់អ្នកជំនួយការងារផ្ទះជាចាំបាច់នៅក្នុងការណែនាំខ្លីៗ មុនពេលចេញដំណើរ)
  - ការធានារ៉ាប់រងដែលចាំបាច់
  - ថ្លៃពិនិត្យសុខភាព
  - ថ្លៃលិខិតបញ្ជាក់ ឬទទួលស្គាល់ជាផ្លូវការ (អគ្គកុងស៊ុលប្រទេសហ្វីលីពីនប្រចាំនៅ ហុងកុងជាអ្នកកំណត់ថ្លៃ)
  - ថ្លៃទិដ្ឋាការ (នាយកដ្ឋានអន្តោប្រវេសន៍ជាអ្នកកំណត់ថ្លៃ)

គំរូវិក័យបត្រនៃការសងលើការចំណាយជំនួសឱ្យអ្នកជំនួយការងារផ្ទះហ្វីលីពីន គឺមាននៅឧបសម្ព័ន្ធទី II ។

**សទ២.២ តើខ្ញុំគួរចំណាយអ្វីខ្លះទៅលើការសងជំនួសឱ្យអ្នកជំនួយការងារផ្ទះខ្ញុំ បើសិនខ្ញុំបន្តកិច្ចសន្យាការងារជាមួយគាត់/នាង ទៀត?**

**ច** អ្នកគួរតែចំណាយទៅឱ្យអ្នកជំនួយការងារផ្ទះអ្នក ទៅលើថ្លៃលិខិតបញ្ជាក់ឬទទួលស្គាល់ជាផ្លូវការដែលពាក់ព័ន្ធនឹងកិច្ចសន្យាម្តងទៀត ដែលប្រមូលដោយកុងស៊ុលនៃប្រទេសរបស់អ្នកជំនួយការងារផ្ទះអ្នក នៅហុងកុង ថ្លៃសេវាដែលកំណត់ដោយនាយកដ្ឋានអន្តោប្រវេសន៍ និងការចំណាយផ្សេងទៀតដោយអ្នកជំនួយការងារផ្ទះអ្នក ដែលទាក់ទងនឹងការបន្តកិច្ចសន្យាការងារម្តងទៀត ដូចដែលបានបញ្ជាក់ក្នុងកថាខណ្ឌទី ៨ នៃកិច្ចសន្យាការងារស្តង់ដារ ។

**សទ២.៣ តើខ្ញុំគួរចំណាយលើថ្លៃដំណើរការ / ឯកសារដល់អ្នកជំនួយការងារផ្ទះរបស់ខ្ញុំ ដែលបានជួលគាត់តាមរយៈទីភ្នាក់ងារជ្រើសរើសនៅហុងកុងដែរឬទេ?**

**ច** វាអាស្រ័យលើអ្វី ដែលទីភ្នាក់ងារជ្រើសរើសបានធ្វើការចំណាយក្នុងនាមតំណាងឱ្យអ្នក និងអាស្រ័យលើអ្នកជំនួយការងារផ្ទះអ្នកបានយកប្រាក់គាត់ផ្ទាល់ទៅបង់លើថ្លៃចាំបាច់ណាមួយ ឬមិនបាន ។ ប្រសិនបើអ្នកបានបង់ប្រាក់ដែលទាក់ទងនឹងការចំណាយទាំងនោះទៅឱ្យទីភ្នាក់ងារជ្រើសរើស អ្នកគួរតែស្នើឱ្យទីភ្នាក់ងារផ្តល់វិក័យបត្រដែលពាក់ព័ន្ធទាំងអស់ដល់អ្នក សម្រាប់ទុកជាភស្តុតាងនៃការទូទាត់ចំណាយ ។

# ៣ ការចំណាយ និងការកាត់ប្រាក់ឈ្នួល

## សម្រាប់និយោជក

**សព.១ តើខ្ញុំអាចធ្វើការព្រមព្រៀងជាមួយអ្នកជំនួយការងារផ្ទះរបស់ខ្ញុំ ដោយផ្តល់ប្រាក់ឈ្នួលឱ្យគាត់តិចជាងប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ (MAW) បានដែរឬទេ តើអ្វីជាប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ (MAW)?**

**ច**

- មិនបានទេ ។ និយោជកមិនអាចធ្វើការព្រមព្រៀងជាមួយអ្នកជំនួយការងារផ្ទះដោយផ្តល់ប្រាក់ឈ្នួលឱ្យគាត់តិចជាងប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់បាននោះទេ ។ ការអនុញ្ញាតឱ្យបញ្ជូនអ្នកជំនួយការងារផ្ទះចូលក្នុងហុងកុង គឺផ្អែកលើព័ត៌មានពិតៗដែលបានផ្ញើរជូននាយកអន្តោប្រវេសន៍ ដោយនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលឱ្យអ្នកជំនួយការងារផ្ទះមិនតិចជាងប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ ។ និយោជកមិនបានបង់ប្រាក់ឈ្នួលតាមទំនើងចិត្ត និងដោយគ្មានហេតុផលត្រឹមត្រូវ ដែលដូចមានចែងក្នុងកិច្ចសន្យាការងារធម្មតា ត្រូវទទួលរងការកាត់ទោស និងផ្តន្ទាទោសដោយពិន័យជាប្រាក់ចំនួន ៣៥០,000 ដុល្លារហុងកុង និងជាប់ពន្ធនាគាររយៈពេល 3 ឆ្នាំ ។ និយោជកអាចនឹងប្រឈមមុខ ដោយការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក្នុងការកុហកបោកប្រាស់មន្ត្រីអន្តោប្រវេសន៍ និងការឃុបឃិតបោកប្រាស់ក្លែងបន្លំ ។ ជនណាដែលត្រូវបានផ្តន្ទាទោសពីបទក្លែងបន្លំត្រូវទទួលរងការកាត់ទោស និងផ្តន្ទាទោសដោយពិន័យជាប្រាក់ចំនួន ១៥០,000 ដុល្លារហុងកុង និងជាប់ពន្ធនាគាររយៈពេល ១៤ ឆ្នាំ ។

**សព.២ តើខ្ញុំគួរផ្តល់ប្រាក់ឈ្នួលដល់អ្នកជំនួយការងារផ្ទះខ្ញុំយ៉ាងដូចម្តេច?**

**ច**

- អ្នកគួរផ្តល់ប្រាក់ឈ្នួលដល់អ្នកជំនួយការងារផ្ទះ តាមរយៈសែក ឬដោយស្វ័យទូទាត់នៅក្នុងគណនីធនាគាររបស់អ្នកជំនួយការងារផ្ទះអ្នក ។ ដើម្បីធ្វើដូចនេះបាន អ្នកត្រូវតែសុំការឯកភាពពីអ្នកជំនួយការងារផ្ទះជាមុនសិន ។ ប្រសិនបើអ្នកជំនួយការងារផ្ទះអ្នកមិនចង់ទទួលយកមធ្យោបាយខាងលើក្នុងការបើកប្រាក់ឈ្នួលរបស់គាត់ អ្នកគួរតែផ្តល់ប្រាក់ឈ្នួលឱ្យគាត់តាមសំណើដែលស្របច្បាប់ ។

- អ្នកត្រូវរក្សាកំណត់ត្រានៃការផ្តល់ប្រាក់ឈ្នួល ឧទា. របាយការណ៍របស់ធនាគារដែលពាក់ព័ន្ធ ។ អ្នកក៏គួរតែផ្តល់វិក័យបត្រសម្រាប់ការផ្តល់ប្រាក់ឈ្នួល និងថ្លៃហូបចុក ហើយស្នើឱ្យអ្នកជំនួយការងារផ្ទះអ្នកទទួលស្គាល់នៃចំនួនទឹកប្រាក់នៅក្នុងវិក័យបត្រ ។

  គំរូនៃវិក័យបត្រប្រាក់ឈ្នួលផ្តល់ឱ្យអ្នកជំនួយការងារផ្ទះមកពីបរទេស (FDHs) គឺមាននៅឧបសម្ព័ន្ធទី IIIក ។

### សណ.៣ តើនៅពេលណាខ្ញុំគួរផ្តល់ប្រាក់ឈ្នួលទៅឱ្យអ្នកជំនួយការងារផ្ទះខ្ញុំ?

**ច**

- អ្នកគួរតែផ្តល់ប្រាក់ឈ្នួលដល់អ្នកជំនួយការងារផ្ទះអ្នក ដោយតិចបំផុតម្តងក្នុងមួយខែ ។ ប្រាក់ឈ្នួលនឹងត្រូវផ្តល់ជូន នៅថ្ងៃចុងក្រោយនៃរយៈពេលដែលបានកំណត់នៃការផ្តល់ប្រាក់ឈ្នួល ។ អ្នកគួរតែផ្តល់ប្រាក់ឈ្នួលដល់អ្នកជំនួយការងារផ្ទះអ្នកឱ្យបានឆាប់តាមដែលអាចធ្វើបាន ប៉ុន្តែបើមានករណីណាមួយកើតឡើង ការផ្តល់ប្រាក់ឈ្នួលមិនត្រូវយូរជាង៧ថ្ងៃបន្ទាប់ពីកាលកំណត់បើកប្រាក់ឈ្នួលចុងក្រោយ ។
- ប្រសិនបើអ្នកចង់ផ្លាស់ប្តូរកាលកំណត់ និងកាលបរិច្ឆេទបើកប្រាក់ឈ្នួល អ្នកគួរជូនដំណឹងដល់អ្នកជំនួយការងារផ្ទះអ្នក និងផ្តល់ប្រាក់ឈ្នួលដែលនៅសល់អោយអស់ ។

ឧទាហរណ៍ អ្នកជំនួយការងារផ្ទះអ្នកបានចាប់ផ្តើមធ្វើការ នៅថ្ងៃទី១ ខែមីនា ។ ប្រសិនបើអ្នកចង់ផ្លាស់ប្តូរកាលកំណត់បើកប្រាក់ឈ្នួលដែលចាប់ផ្តើមពីថ្ងៃទី ១៦ រាល់ខែ អ្នកគួរតែផ្តល់ប្រាក់ឈ្នួលដែលនៅសល់ ១៥ថ្ងៃឱ្យអស់សិន (ឧទាហរណ៍ពីថ្ងៃទី១ដល់១៥) កំឡុងពេលប្រាំពីរថ្ងៃបន្ទាប់ពីថ្ងៃទី១៥ ខែមីនា មុនពេលអ្នកផ្តល់ប្រាក់ឱ្យ គាត់ / នាង នៅកាលកំណត់ថ្មីសម្រាប់បើកប្រាក់ឈ្នួលក្នុងខែមេសា ។

## សម្រាប់អ្នកជំនួយការងារផ្ទះ

### សណ.៤ តើខ្ញុំគួរធ្វើដូចម្តេច នៅពេលនិយោជករបស់ខ្ញុំបានបើកប្រាក់ឈ្នួលមកឱ្យខ្ញុំហើយ?

**ច** អ្នកគួរតែពិនិត្យចំនួនទឹកប្រាក់ដែលបានផ្តល់មកឱ្យអ្នក ។ ប្រសិនជាចំនួនគ្រប់ត្រឹមត្រូវហើយ អ្នកគួរតែទទួលស្គាល់ចំនួនទឹកប្រាក់នៅក្នុងវិក័យបត្រដែលបានរៀបចំដោយនិយោជករបស់អ្នក ។

### សណ.៥ តើខ្ញុំគួរធ្វើដូចម្តេច បើនិយោជករបស់ខ្ញុំផ្តល់ប្រាក់ឈ្នួលតិចជាងប្រាក់ដែលបានកំណត់ឱ្យខ្ញុំ?

**ច** ប្រសិនបើចំនួនទឹកប្រាក់ដែលផ្តល់ឱ្យ តិចជាងប្រាក់ឈ្នួលដែលចែងនៅក្នុងកិច្ចសន្យាការងារ អ្នកគួរតែពិនិត្យ និងសួរនិយោជករបស់អ្នកប្រសិនបើការគណនាចំនួនប្រាក់មិនត្រឹមត្រូវ ។ មិនត្រូវទទួលស្គាល់វិក័យបត្រប្រាក់ឈ្នួលនេះ ។ ប្រសិនបើគ្មានការពន្យល់ឱ្យជាក់លាក់ពីនិយោជករបស់អ្នកចំពោះការបើកប្រាក់មិនគ្រប់ចំនួននោះ អ្នកគួរតែរាយការណ៍ករណីនេះភ្លាមៗទៅសាខានៃការិយាល័យផ្នែកទំនាក់ទំនងការងារ នៃនាយកដ្ឋានការងារ (មើលជំពូកទី ១២) ។

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

### សណ.៦ តើនិយោជកអាចកាត់ប្រាក់ឈ្នួលអ្នកជំនួយការងារផ្ទះ ដើម្បីទូទាត់សំណងលើការខូចខាតទំនិញដែល គាត់/នាង បានបង្កឡើងដែរឬទេ? តើមានចំណុចណាផ្សេងទៀតដែលនិយោជកអាចកាត់ប្រាក់ឈ្នួលពីអ្នកជំនួយការងារផ្ទះ?

**ច**

- និយោជកអាចកាត់ថ្លៃលើការខូចខាត ឬបាត់បង់ទំនិញ ឬទ្រព្យសម្បត្តិដែលកើតឡើងពីការធ្វេសប្រហែស ឬកំហុសរបស់អ្នកជំនួយការងារផ្ទះ ។ ក្នុងករណីណាក៏ដោយ ចំនួនទឹកប្រាក់សរុបដែលត្រូវកាត់ចេញគឺសមមូលទៅនឹងតម្លៃនៃការខូចខាត ឬការបាត់បង់ ប៉ុន្តែមិនលើសពី ៣០០ ដុល្លារហុងកុង ។ ថ្លៃសរុបនៃការកាត់គឺមិនត្រូវលើសពីមួយភាគបួននៃប្រាក់ឈ្នួលដែលអាចផ្តល់ឱ្យអ្នកជំនួយការងារផ្ទះនៅកាលកំណត់បើកប្រាក់ឈ្នួលនោះ ។

- និយោជកក៏អាចធ្វើការកាត់ប្រាក់ឈ្នួលពីអ្នកជំនួយការងារផ្ទះ ក្រោមកាលៈទេសៈដូចខាងក្រោម៖
    - ការកាត់សម្រាប់ការអវត្តមានពីការងារ ។ ចំនួនទឹកប្រាក់សរុបដែលត្រូវកាត់ចេញគួរតែសមាមាត្រទៅនឹងរយៈពេលដែលអ្នកជំនួយការងារផ្ទះអវត្តមានពីការងារ ។
    - ការកាត់សម្រាប់ការសងជាមុននូវរឿងណាមួយ ឬនិយោជកផ្តល់ប្រាក់ឈ្នួលលើសចំនួនដល់អ្នកជំនួយការងារផ្ទះ ។ ថ្លៃសរុបនៃការកាត់ប្រាក់ឈ្នួលមិនត្រូវលើសពីមួយភាគបួននៃប្រាក់ឈ្នួលដែលបើកជូនអ្នកជំនួយការងារផ្ទះតាមកាលកំណត់បើកប្រាក់ឈ្នួល ។
    - ការកាត់ដោយសារតែមានការស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកជំនួយការងារផ្ទះក្នុងការសុំប្រាក់កម្ចីពីនិយោជក ។
    - ការកាត់គឺចាំបាច់តម្រូវឱ្យកាត់ ឬយោងតាមការអនុម័តណាមួយដែលត្រូវបានធ្វើឡើងដោយទាក់ទងទៅនឹងប្រាក់ឈ្នួលរបស់អ្នកជំនួយការងារផ្ទះ ។
- ទាល់តែមានការសម្រេចយល់ព្រមជាលាយលក្ខណ៍អក្សរពីគណៈកម្មការការងារ ថ្លៃសរុបនៃការកាត់ប្រាក់ឈ្នួលដែលសម្រេចនៅថ្ងៃកំណត់បើកប្រាក់ឈ្នួលនាខែណាមួយ គឺមិនត្រូវលើសពីមួយភាគកន្លះដងនៃប្រាក់ឈ្នួលដែលបានផ្តល់ឱ្យកំឡុងពេលនោះទេ ដោយមិនរាប់បញ្ចូលអ្នកដែលអវត្តមានមិនបានធ្វើការ ។

### ស៣.៧ តើនឹងមានផលវិបាកអ្វីខ្លះ នៅពេលនិយោជកខកខានផ្តល់ប្រាក់ឈ្នួលមិនទាន់ពេល ទៅឱ្យអ្នកជំនួយការងារផ្ទះ?

**ច**

- ប្រសិនបើនិយោជកខកខានផ្តល់ប្រាក់ឈ្នួលមិនទាន់ពេល ទៅឱ្យអ្នកជំនួយការងារផ្ទះ ក្នុងកំឡុងពេលប្រាំពីរថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលផ្តល់ឱ្យ គាត់ / នាងត្រូវ៖
    - ផ្តល់ការប្រាក់លើចំនួនប្រាក់ឈ្នួលដែលនៅសល់មិនទាន់ផ្តល់ឱ្យអ្នកជំនួយការងារផ្ទះ និង
    - ទទួលរងការកាត់ទោស និងផ្តន្ទាទោសដោយផាកពិន័យ ៣៥០,០០០ ដុល្លារហុងកុង និងជាប់ពន្ធនាគាររយៈពេលបីឆ្នាំ ។
- ប្រសិនប្រាក់ឈ្នួលមិនទាន់បានផ្តល់ក្នុងកំឡុងពេលមួយខែបន្ទាប់ពីកាលបរិច្ឆេទបើកប្រាក់ឱ្យអ្នកជំនួយការងារផ្ទះនោះ អ្នកជំនួយការងារផ្ទះអាចចាត់ទុកថាកិច្ចសន្យានេះត្រូវបានបញ្ឈប់ដោយនិយោជកដោយគ្មានការជូនដំណឹង ។ ដូចនេះ និយោជកត្រូវផ្តល់ប្រាក់ដល់អ្នកជំនួយការងារផ្ទះ ជំនួសការមិនបានជូនដំណឹងមុន បន្ថែមលើច្បាប់ដទៃទៀត និងផ្តល់ប្រាក់លើការបញ្ចប់កិច្ចសន្យាជាមួយអ្នកជំនួយការងារផ្ទះ(មើលជំពូកទី៨) ។

# ៤ ថ្ងៃឈប់សម្រាកធម្មតា ថ្ងៃឈប់សម្រាកបុណ្យជាតិ និងច្បាប់ឈប់សម្រាក

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

**ស៤.១ យោងតាមច្បាប់បទប្បញ្ញត្តិការងារ តើអ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានការឈប់សម្រាកបែបណា?**

**ច**

- យោងតាមច្បាប់បទប្បញ្ញត្តិការងារ អ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានការឈប់សម្រាកដូចខាងក្រោម ៖
  - ថ្ងៃឈប់សម្រាកធម្មតា
  - ថ្ងៃឈប់សម្រាកបុណ្យជាតិ និង
  - ច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ។
- ប្រសិនបើភាគីទាំងពីរយល់ព្រមបន្តកិច្ចសន្យាជាថ្មីជាមួយគ្នា មុនពេលចាប់ផ្តើមអនុវត្តកិច្ចសន្យាថ្មី អ្នកជំនួយការងារផ្ទះអាចត្រឡប់ទៅប្រទេសកំណើតរបស់ គាត់ / នាង កដោយនិយោជកត្រូវផ្តល់ការចំណាយឱ្យ គាត់ / នាង សម្រាប់វិស្សមកាលនេះដែលមានរយៈពេលមិនលើសពីប្រាំពីរថ្ងៃ ដោយយោងតាមកិច្ចសន្យាការងារស្តង់ដារ ។
- រាល់កំណត់ត្រានៃច្បាប់ឈប់សម្រាក និងការចំណាយទៅឱ្យអ្នកជំនួយការងារផ្ទះគួរតែរក្សាទុកឱ្យបានល្អ ដើម្បីចៀសវាងការកើតឡើងនូវវិវាទទៅថ្ងៃមុខ ។

## ថ្ងៃឈប់សម្រាកធម្មតា

## សម្រាប់និយោជក

**ស៤.២ តើខ្ញុំគួរតែកំណត់ថ្ងៃឈប់សម្រាកធម្មតាដល់អ្នកជំនួយការងារផ្ទះខ្ញុំដោយរបៀបណា?**

**ច**

- អ្នកគួរតែផ្តល់ថ្ងៃឈប់សម្រាកធម្មតាយ៉ាងតិចមួយថ្ងៃរាល់មួយសប្តាហ៍ ដល់អ្នកជំនួយការងារផ្ទះអ្នក ។ ថ្ងៃឈប់សម្រាកចំនួនមួយថ្ងៃដែលបានផ្តល់ គឺត្រូវស្ថិតនៅកំឡុងពេលមួយដែលមិនតិចជាង ២៤ ម៉ោង ។
- អ្នកត្រូវតែរៀបចំថ្ងៃឈប់សម្រាកធម្មតា និងអាចឱ្យអ្នកជំនួយការងារផ្ទះទទួលបានការឈប់សម្រាកដោយកំណត់ផ្អែកលើមូលដ្ឋានទៀងទាត់ ឬមិនទៀងទាត់ ។ ប្រសិនបើថ្ងៃឈប់សម្រាកកំណត់តាមមូលដ្ឋានមិនទៀងទាត់ អ្នកគួរតែជូនដំណឹងដល់អ្នកជំនួយការងារផ្ទះអ្នក អំពីថ្ងៃឈប់សម្រាករបស់គាត់ មុនពេលដើមខែនីមួយៗ ។

### សង៤.៣ តើខ្ញុំអាចអោយអ្នកជំនួយការងារផ្ទះខ្ញុំ ធ្វើការនៅថ្ងៃឈប់សម្រាករបស់ គាត់ / នាង បានដែរឬទេ?

ច

- មិនបានទេ ។ អ្នកមិនត្រូវអោយអ្នកជំនួយការងារផ្ទះអ្នកធ្វើការនៅថ្ងៃឈប់សម្រាករបស់ គាត់ / នាង នោះឡើយ លើកលែងតែមានការបន្ទាន់ ដែលមិនបានគ្រោងទុកជាមុន ។ និយោជកណាដែលបង្ខំឱ្យអ្នកជំនួយការងារផ្ទះធ្វើការនៅថ្ងៃឈប់សម្រាក គឺចាត់ជាការប្រព្រឹត្តល្មើសផ្ទុយពីច្បាប់បទប្បញ្ញត្តិការងារ ។
- ប៉ុន្តែប្រសិនបើមានការយល់ព្រមពីអ្នកជំនួយការងារផ្ទះអ្នកដើម្បីធ្វើការនៅថ្ងៃឈប់សម្រាក អ្នកអាចជំនួសថ្ងៃផ្សេងទៀតឱ្យអ្នកជំនួយការងារផ្ទះបានឈប់ជំនួសថ្ងៃឈប់សម្រាកដែលបានកំណត់ឱ្យគាត់ ។ ថ្ងៃឈប់ដែលបានជំនួសឱ្យថ្ងៃឈប់សម្រាកធម្មតា ត្រូវតែផ្តល់ជូនអ្នកជំនួយការងារផ្ទះនៅក្នុងខែដូចគ្នា និងមុនពេលថ្ងៃឈប់សម្រាកធម្មតាដែលបានកំណត់ ឬកំឡុងពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃឈប់សម្រាកធម្មតា ។

### សង៤.៤ តើខ្ញុំអាចអោយអ្នកជំនួយការងារផ្ទះខ្ញុំ ធ្វើការបន្ទាប់ពី គាត់ / នាង បានត្រលប់ទៅផ្ទះនៅថ្ងៃឈប់សម្រាកបានដែរឬទេ?

ច អ្នកមិនអាចបង្ខំឱ្យអ្នកជំនួយការងារផ្ទះអ្នកធ្វើការ នៅថ្ងៃឈប់សម្រាកលំហែរបស់ គាត់ /នាងបានឡើយ ។ ប៉ុន្តែ គាត់ / នាងអាចមានសិទ្ធិសម្រេចក្នុងការស្ម័គ្រចិត្តធ្វើការនៅថ្ងៃឈប់សម្រាករបស់ គាត់ / នាង បាន ។

## ថ្ងៃឈប់សម្រាកបុណ្យជាតិ

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

### សង៤.៥ មុនពេលអ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានថ្ងៃឈប់សម្រាកបុណ្យជាតិក្នុងមួយឆ្នាំ តើគាត់ / នាងគួរបម្រើការងារចាប់ពីរយៈពេលប៉ុន្មានឡើងទៅ?

ច

- អ្នក ជួយ ក្នុង ស្រុក ក្រៅ ស្រុក ទាំង អស់ មិន គិត ពី រយៈ ពេល នៃ សេវា កម្ម របស់ ពួក គេ មាន សិទ្ធិ ទទួល បាន ថ្ងៃ ឈប់ សម្រាក តាម ច្បាប់ ដូច ខាង ក្រោម ៖
  - ថ្ងៃទីមួយនៃខែមករា
  - ពិធីបុណ្យចូលឆ្នាំចិន
  - ថ្ងៃទីពីរនៃថ្ងៃបុណ្យចូលឆ្នាំចិន
  - ថ្ងៃទីបីនៃថ្ងៃបុណ្យចូលឆ្នាំចិន
  - ថ្ងៃបុណ្យឆេងម៉េង
  - ទិវាពលកម្ម (ខែឧសភា១ថ្ងៃទី)
  - ខួបកំណើតព្រះពុទ្ធ (បាន បន្ថែម ថ្មី ពី 2022)
  - ពិធីបុណ្យ Tuen Ng (បុណ្យទូកនាគ)
  - ថ្ងៃបន្ទាប់ពីពិធីបុណ្យពាក់កណ្តាលសរទរដូវចិន
  - ពិធីបុណ្យ Chung Yeung (សែនផ្នូរដូនតា)

- ទិវាសុលសុីសរដូវត្រជាក់របស់ចិន ឬថ្ងៃបុណ្យណូអែល (ផ្អែកលើការសម្រេចចិត្តរបស់និយោជក)
- ទិវាបង្កើតតំបន់រដ្ឋបាលពិសេសហុងកុង (ថ្ងៃទី១ខែកក្កដា) និង
- ថ្ងៃបុណ្យជាតិ (ថ្ងៃទី១ខែតុលា) ។
- ថ្ងៃសប្តាហ៍ដំបូងបន្ទាប់ពីថ្ងៃបុណ្យណូអែល (ទើបបន្ថែមពីឆ្នាំ 2024)

ថ្ងៃ ឈប់ សម្រាក តាម ច្បាប់ បន្ថែម ចាប់ ពី ឆ្នាំ 2026 ហើយ បន្ទាប់ មក ត្រូវ បាន ដាក់ បញ្ចាំ ដូច ខាង ក្រោម៖

| ឆ្នាំខាល | បាន បន្ថែម ថ្មី ថ្ងៃ ឈប់ សម្រាក តាម ច្បាប់ | ចំនួន សរុប នៃ ថ្ងៃ ឈប់ សម្រាក តាម ច្បាប់ |
|---|---|---|
| ចាប់ពីឆ្នាំ 2026 មកវិញ | ថ្ងៃ ច័ន្ទ បុណ្យ អុឺស្ទើរ | 15 |
| ចាប់ពីឆ្នាំ 2028 មកវិញ | ថ្ងៃ សុក្រ ល្អ | 16 |
| ចាប់ពីឆ្នាំ 2030 មកវិញ | ថ្ងៃ បន្ទាប់ ពី ថ្ងៃ សុក្រ ល្អ | 17 |

- អ្នកជួនួយការងារផ្ទះដែលបានបេ រមីការងារឱ យនិយោជកបានរយៈពេលបីខែមុនៃថ្ងបុណ យជាតិណាមួ យគាត់ / នាង គាចំនសិទ្ធិទទួលបានៃថ្ងឈប់ស រំកបុណ យជាតិដោយំន រេបាក់ឈ្នួលបាន ។

## សម្រាប់និយោជក

**សង៤.៦ តើខ្ញុំអាចអោយអ្នកជំនួយការងារផ្ទះខ្ញុំ ធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យជាតិបានដែរឬទេ?**

**ច** បាន ប៉ុន្តែអ្នកត្រូវតែផ្តល់ឱ្យគាត់/នាង ដូចជា៖

- ការជូនដំណឹងជាមុនដោយមិនតិចជាង ៤៨ ម៉ោង និង
- ផ្តល់ថ្ងៃឈប់សម្រាកបុណ្យណាផ្សេងជំនួស ក្នុងកំឡុងពេល ៦០ថ្ងៃមុន ឬ៦០ថ្ងៃបន្ទាប់ពីថ្ងៃឈប់សម្រាកបុណ្យជាតិដែលតម្រូវឱ្យ គាត់ / នាង ធ្វើការ ។

**សង៤.៧ តើខ្ញុំអាចអោយអ្នកជំនួយការងារផ្ទះខ្ញុំ ឈប់ទទួលបានថ្ងៃឈប់សម្រាកបុណ្យជាតិ ដោយជំនួសមកវិញនូវប្រាក់ឈ្នួលបន្ថែមដែលមានការយល់ព្រមពី គាត់ / នាង បានដែរឬទេ?**

**ច**
- មិនបានទេ ។ អ្នកមិនត្រូវធ្វើទម្រង់ការចំណាយណាមួយសម្រាប់ផ្តល់ឱ្យអ្នកជំនួយការងារផ្ទះអ្នក ក្នុងការជំនួសថ្ងៃឈប់សម្រាកបុណ្យជាតិរបស់ គាត់ / នាង ឡើយ ។
- និយោជកណាដែលប្រព្រឹត្តផ្ទុយពីការចែងដូចខាងលើនេះ នឹងត្រូវទទួលការកាត់ទោស និងផ្តន្ទាទោសដោយផាកពិន័យ ៥០,០០០ដុល្លារហុងកុង ។

**សង៤.៨ ប្រសិនបើថ្ងៃឈប់សម្រាកបុណ្យជាតិនោះ នៅចំថ្ងៃតែមួយនឹងថ្ងៃឈប់សម្រាកធម្មតារបស់អ្នកជំនួយការងារផ្ទះខ្ញុំ តើខ្ញុំមានកាតព្វកិច្ចក្នុងការជំនួសថ្ងៃឈប់សម្រាកបុណ្យជាតិណាផ្សេងទៀតដល់ គាត់ / នាង ដែរឬទេ?**

**ច** ពិតប្រាកដណាស់គឺអ្នកមានកាតព្វកិច្ច ប្រសិនបើថ្ងៃឈប់សម្រាកបុណ្យជាតិនោះ នៅចំថ្ងៃតែមួយនឹងថ្ងៃឈប់សម្រាកធម្មតា អ្នកគួរតែជំនួសថ្ងៃឈប់សម្រាកបុណ្យជាតិណាផ្សេងទៀត ដែលស្ថិតនៅថ្ងៃបន្ទាប់ពីថ្ងៃឈប់សម្រាកធម្មតា និងមិនចំថ្ងៃឈប់សម្រាកបុណ្យជាតិទៀត ។

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

### សឹ.៩ តើអ្នកជំនួយការងារផ្ទះគួរតែទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួនប៉ុន្មានថ្ងៃ ក្នុងមួយឆ្នាំ?

ច អ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល បន្ទាប់ពី គាត់ / នាង បានបម្រើការងារឱ្យនិយោជកតែម្នាក់ ក្នុងរយៈពេល១២ខែ ។ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលអ្នកជំនួយការងារផ្ទះទទួលបាននោះ នឹងកើនឡើងជាបន្តបន្ទាប់ចាប់ពីចំនួនប្រាំពីរថ្ងៃ រហូតដល់ចំនួន១៤ថ្ងៃ ផ្អែកតាមរយៈពេលនៃការបម្រើការងាររបស់ គាត់ / នាង ដូចខាងក្រោម៖

| ចំនួនឆ្នាំនៃការបម្រើការងារ | ចំនួនថ្ងៃក្នុងមួយឆ្នាំ នៃច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល |
|---|---|
| ១ | ៧ |
| ២ | ៧ |
| ៣ | ៨ |
| ៤ | ៩ |
| ៥ | ១០ |
| ៦ | ១១ |
| ៧ | ១២ |
| ៨ | ១៣ |
| ចាប់ពី ៩ | ១៤ |

ឧទាហរណ៍៖ អ្នកជំនួយការងារផ្ទះទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ចំនួនប្រាំបួនថ្ងៃ បន្ទាប់ពី គាត់ / នាង បានបំពេញការងារអស់រយៈពេលបួនឆ្នាំ ដែលនៅកំឡុងពេលបន្តកិច្ចសន្យាលើកទីពីរដែលមានសុពលភាពពីរឆ្នាំជាមួយនិយោជករបស់ គាត់ / នាង ។

### សឹ.១០ តើអ្នកណាជាអ្នកកំណត់ពេលវេលាដែលស្ត្រីជំនួយការងារផ្ទះអាចមានសិទ្ធទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយទទួលបានប្រាក់ឈ្នួល?

ច អ្នកជំនួយការងារផ្ទះត្រូវប្រើច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយទទួលបានប្រាក់ឈ្នួលដែល គាត់មាន ក្នុងកំឡុងពេលយ៉ាងយូរ១២ខែបន្ទាប់ តាមការកំណត់របស់និយោជកក្រោយពីបានពិភាក្សាជាមួយអ្នកជំនួយការផ្ទះ ហើយនិយោជកត្រូវចេញនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់អ្នកជំនួយការងារផ្ទះ យ៉ាងតិច១៤ថ្ងៃជាមុន ។

### សឹ.១១ តើច្បាប់ឈប់សម្រាកប្រចាំឆ្នាំគួរតែរួមបញ្ចូលទាំងថ្ងៃឈប់សម្រាកធម្មតា និងថ្ងៃឈប់សម្រាកបុណ្យជាតិជាមួយគ្នាបានដែរឬទេ?

ច មិនបានទេ ។ ថ្ងៃឈប់សម្រាកធម្មតា ឬថ្ងៃឈប់សម្រាកបុណ្យជាតិដែលប្រព្រឹត្តទៅចំថ្ងៃជាមួយគ្នានឹងច្បាប់ឈប់សម្រាកប្រចាំឆ្នាំ នឹងត្រូវតែបានលើក ឬជំនួសទៅថ្ងៃណាផ្សេងទៀត ។

### សឥ.១២ តើមូលហេតុអ្វី ឬតាមលក្ខខណ្ឌអ្វីដែលគួរមានការផ្តល់ជូនបន្ថែមនូវច្បាប់ឈប់សម្រាកវិស្សមកាល ពីលើច្បាប់ឈប់សម្រាកប្រចាំឆ្នាំ?

**ច** ប្រសិនបើនិយោជក និងអ្នកជំនួយការងារផ្ទះបានយល់ព្រមបន្តកិច្ចសន្យាជាថ្មីជាមួយគ្នា នោះនិយោជកគួរតែផ្តល់នូវច្បាប់ឈប់សម្រាកវិស្សមកាលដល់អ្នកជំនួយការងារផ្ទះ ដោយយ៉ាងតិចប្រាំពីរថ្ងៃសម្រាប់ការត្រឡប់ទៅប្រទេសកំណើតរបស់ គាត់ / នាង វិញ មុនពេលចាប់ផ្តើមអនុវត្តកិច្ចសន្យាថ្មី ដោយយោងទៅតាមកថាខណ្ឌទី១៣នៃកិច្ចសន្យាការងារស្តង់ដារ ។ ប៉ុន្តែ ច្បាប់ឈប់សម្រាកវិស្សមកាលដោយមានប្រាក់ឈ្នួល ឬគ្មានប្រាក់ឈ្នួល អាស្រ័យលើលក្ខខណ្ឌដែលបានព្រមព្រៀងនៅក្នុងកិច្ចសន្យា ។

### សឥ.១៣ តើនិយោជកអាចតម្រូវឱ្យអ្នកជំនួយការងារផ្ទះរបស់ គាត់ / នាង ទទួលបានច្បាប់ឈប់សម្រាកដោយគ្មានប្រាក់ឈ្នួល នៅពេលនិយោជកទៅក្រៅប្រទេសបានដែរឬទេ?

**ច** ច្បាប់ឈប់សម្រាកដោយគ្មានប្រាក់ឈ្នួល ត្រូវរៀបចំឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរជាមុនសិន ។ និយោជកមិនអាចអត្តនោម័តដោយខ្លួនឯងក្នុងការតម្រូវឱ្យអ្នកជំនួយការងារផ្ទះរបស់ គាត់ / នាង ទទួលបានច្បាប់ឈប់សម្រាកដោយគ្មានប្រាក់ឈ្នួល នោះឡើយ ។

## សម្រាប់និយោជក

### សឥ.១៤ តើខ្ញុំគួរតែផ្តល់ច្បាប់ឈប់សម្រាកប្រចាំឆ្នាំដល់អ្នកជំនួយការងារផ្ទះខ្ញុំ នៅពេលដែលបញ្ចប់កិច្ចសន្យាការងារតាមកាលកំណត់ ឬបញ្ចប់មុនពេលកំណត់បានដែរឬទេ?

**ច**

- នៅពេលមានការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ អ្នកគួរតែផ្តល់ឱ្យអ្នកជំនួយការងារផ្ទះអ្នកដែលបានបម្រើការងារអស់រយៈពេល១២ខែ នូវប្រាក់ជំនួសឱ្យច្បាប់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ឬគាត់ / នាងមិនទាន់បានសុំ ។ ចំពោះអ្នកជំនួយការងារផ្ទះដែលបានបម្រើការងារបានតែបីខែ តិចជាងកាលកំណត់១២ខែក្នុងការទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ (ពោលគឺ រយៈពេលណាមួយបន្ទាប់ពីការចាប់ផ្តើមបម្រើការងារ ក្រោមចំនួន១២ខែម្តង) គាត់ / នាងមានសិទ្ធិទទួលបានប្រាក់ដែលទូទាត់តាមសមាមាត្រនៃច្បាប់ឈប់សម្រាកសរុបប្រចាំឆ្នាំ ប្រសិនបើកិច្ចសន្យាការងារដែលបញ្ចប់មុនពេលកំណត់នោះ កើតឡើងពីមូលហេតុណាមួយផ្សេងក្រៅពីការបញ្ឈប់ ឬបណ្តេញចេញដោយសារតែគាត់ / នាងបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ។
- *ឧទាហរណ៍ ៖* ប្រសិនបើអ្នកជំនួយការងារផ្ទះអ្នកបានសុំលាឈប់ ឬអ្នកបានបញ្ឈប់គាត់ / នាងបន្ទាប់ពីបានបម្រើការងារបានចំនួន១៨ខែ ហើយមិនទាន់បានសុំច្បាប់ឈប់សម្រាកណាមួយនៅឡើយ អ្នកគួរតែផ្តល់ឱ្យគាត់ / នាងនូវប្រាក់ជំនួសឱ្យច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ដោយគិតពីការបំពេញការងារបានរយៈពេល១២ខែដំបូង (ពោលគឺច្បាប់ចំនួន៧ថ្ងៃ) សម្រាប់រយៈពេលដែលនៅសេសសល់ (ពោលគឺ ៧ ថ្ងៃ + ៣.៥ ថ្ងៃ = ១០.៥ ថ្ងៃ) ។
- ប៉ុន្តែ ប្រសិនបើក្នុងករណីអ្នកជំនួយការងារផ្ទះអ្នកដែលបានបម្រើការងារបាន១៨ខែហើយ តែត្រូវបានបញ្ឈប់ដោយសារតែគាត់ / នាងបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ នោះអ្នកនឹងត្រូវផ្តល់ឱ្យគាត់ / នាងនូវប្រាក់ជំនួសឱ្យច្បាប់ឈប់សម្រាកប្រចាំឆ្នាំតែ១២ខែដំបូងរបស់គាត់/នាងប៉ុណ្ណោះ ពោលគឺចំនួន៧ថ្ងៃ ។

# ៥ របបថែទាំសុខភាព និងប្រាក់ឧបត្ថម្ភនៅពេលមានជម្ងឺ

## សម្រាប់និយោជក

**សឥ.១ តើខ្ញុំគួរតែបង់ ឬផ្ដល់ថ្លៃព្យាបាលឱ្យអ្នកជំនួយការងារផ្ទះខ្ញុំដែរឬទេ នៅពេលដែលគាត់ / នាងមានជម្ងឺ ឬរងរបួស?**

ច

- ពិតប្រាកដណាស់អ្នកគួរតែបង់ ។ នៅពេលដែលអ្នកជំនួយការងារផ្ទះអ្នកមានជម្ងឺ ឬរងរបួស អ្នកត្រូវផ្ដល់របបថែទាំសុខភាពដោយឥតគិតថ្លៃ ដល់គាត់ / នាង មិនថាវាកើតឡើងដោយការធ្វើការ ឬមិនមែនក៏ដោយ ។ របបថែទាំសុខភាពដោយឥតគិតថ្លៃរួមមានការប្រឹក្សាផ្នែកវេជ្ជសាស្ត្រ ការព្យាបាលថែទាំនៅមន្ទីរពេទ្យ និងការព្យាបាលទន្តិកជាបន្ទាន់ ។ ដូចនេះ អ្នកគួរតែអនុវត្តតាមគោលនយោបាយធានារ៉ាប់រង ជាមួយការផ្ដល់សេវាទាំងអស់លើផ្នែកវេជ្ជសាស្ត្រ និងការស្នាក់នៅមន្ទីរពេទ្យសម្រាប់អ្នកជំនួយការងារផ្ទះអ្នក ។ អ្នកក៏អាចសម្រេចលើការអនុវត្តតាមគោលនយោបាយធានារ៉ាប់រងដែលផ្ដល់នូវសេវាទាំងអស់លើផ្នែកវេជ្ជសាស្ត្រ និងការស្នាក់នៅមន្ទីរពេទ្យ ហើយអាចបំពេញទៅតាមលក្ខខណ្ឌដែលមានចែង នៅក្នុងច្បាប់បទប្បញ្ញត្តិនៃការសងជម្ងឺចិត្តរបស់បុគ្គលិក ក្នុងពេលតែមួយបាន ។ និយោជកត្រូវបានណែនាំឱ្យរក្សាច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្រដែលផ្ដល់ដោយ FDH ឱ្យបានត្រឹមត្រូវ ។

- ដើម្បីកុំឱ្យមានមន្ទិលសង្ស័យ កិច្ចសន្យាការងារស្ដង់ដារបានកែសម្រួលឡើងវិញ និងបានផ្សព្វផ្សាយណែនាំនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៣ ដោយកិច្ចសន្យាថ្មីនេះបានបញ្ជាក់ច្បាស់ថា និយោជកនឹងមិនទទួលខុសត្រូវលើការផ្ដល់របបថែទាំសុខភាពដោយឥតគិតថ្លៃ កំឡុងពេលដែលអ្នកជំនួយការងារផ្ទះចាកចេញពីហុងកុងដោយការសម្រេចចិត្តដោយខ្លួនឯង និងដោយសារតែមូលហេតុផ្ទាល់ខ្លួនរបស់គាត់ / នាង ឧទាហរណ៍ ៖ សុំច្បាប់ឈប់សម្រាកដើម្បីទៅលេងស្រុកកំណើត ។

**សឥ.២ តើខ្ញុំអាចយកគ្រូពេទ្យផ្ទាល់ម្នាក់សម្រាប់ព្យាបាលមើលជម្ងឺឱ្យអ្នកជំនួយការងារផ្ទះខ្ញុំ នៅពេលគាត់ / នាងមានជម្ងឺ ឬរងរបួសបានដែរឬទេ?**

ច យោងតាមកិច្ចសន្យាការងារ អ្នកជំនួយការងារផ្ទះអាចទទួលយករបបថែទាំសុខភាពពីគ្រូពេទ្យដែលនិយោជកបានយកមកនោះបាន ទាល់តែគ្រូពេទ្យនោះត្រូវបានទទួលស្គាល់ ឬចុះបញ្ជីក្នុងការអនុញ្ញាតឱ្យព្យាបាល ។ អ្នកគួរតែសុំការយល់ព្រមពីអ្នកជំនួយការងារផ្ទះអ្នកជាមុនសិន ដើម្បីជ្រើសយកគ្រូពេទ្យមួយណាដែលអាចផ្ដល់ការប្រឹក្សាខាងវេជ្ជសាស្ត្រ នៅពេលអ្នកជំនួយការងារផ្ទះមានជម្ងឺ ឬរងរបួស ។

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

**សឥ.៣ តើមានលក្ខខណ្ឌអ្វីខ្លះដែលអ្នកជំនួយការងារផ្ទះអាចទទួលបានប្រាក់ឧបត្ថម្ភពេលមានជម្ងឺ?**

ច

- និយោជកគួរតែផ្ដល់ប្រាក់ឧបត្ថម្ភពេលមានជម្ងឺដល់អ្នកជំនួយការងារផ្ទះ ក្នុងករណី ៖
  - គាត់ / នាងបានបង្កើនចំនួនច្បាប់ឈឺដែលមានប្រាក់ឈ្នួលគ្រប់គ្រាន់

- ច្បាប់ឈឺដែលបានសុំ គឺយ៉ាងតិចបួនថ្ងៃជាប់ៗគ្នា និង
- ច្បាប់ឈឺដែលបានសុំ ត្រូវមានវេជ្ជបញ្ជាត្រឹមត្រូវដើម្បីបញ្ជាក់ (ទាក់ទងនឹងការពិនិត្យសុខភាពរបស់ជំនួយការក្នុងផ្ទះទាក់ទងនឹងការមានផ្ទៃពោះរបស់ពួកគេ វាក៏ត្រូវមានការបញ្ជាក់ផងដែរពីលិខិតបញ្ជាក់វត្តមានសម្គាល់ទី 1 ក្រៅពីលិខិតបញ្ជាក់របស់គ្រូពេទ្យ) ។

- ចំនួនច្បាបឈឺដែលមានប្រាក់ឈ្នួល ត្រូវបានបង្កើនតាមអត្រាដែលគិតសម្រាប់ច្បាប់ឈឺដែលមានប្រាក់ឈ្នួលចំនួនពីរថ្ងៃ សម្រាប់អ្នកជំនួយការងារផ្ទះដែលបានបំពេញការងារបាន១២ខែដំបូង និងបង្កើនតាមអត្រាដែលគិតសម្រាប់ច្បាប់ឈឺដែលមានប្រាក់ឈ្នួលចំនួនបួនថ្ងៃ សម្រាប់សម្រាប់អ្នកជំនួយការងារផ្ទះដែលបានបំពេញការងារបាន១២ខែបន្តទៅទៀត ។ ចំនួនច្បាបឈឺដែលមានប្រាក់ឈ្នួលត្រូវបានបង្កើននៅពេលបានបំពេញការងារ១២ខែដោយពេញលេញ ប៉ុន្តែការបង្កើនគឺយ៉ាងច្រើនត្រឹមចំនួន១២០ថ្ងៃនៅពេលណាមួយ ។

**សទ.៤ តើអត្រានៃប្រាក់ឧបត្ថម្ភនៅពេលមានជម្ងឺ មានចំនួនប៉ុន្មាន? តើនៅពេលណាដែលនិយោជកគួរតែផ្តល់វាទៅឱ្យអ្នកជំនួយការងារផ្ទះ?**

**ច** អត្រាប្រចាំថ្ងៃនៃការគិតប្រាក់ឧបត្ថម្ភនៅពេលមានជម្ងឺ គឺស្មើនឹងបួនភាគប្រាំនៃប្រាក់ឈ្នួលប្រចាំថ្ងៃដែលគិតជាមធ្យម* របស់អ្នកជំនួយការងារផ្ទះ ។ ការផ្តល់ប្រាក់ឧបត្ថម្ភនេះ គឺមិនត្រូវយូរជាងការផ្តល់ប្រាក់ឈ្នួលធម្មតាឡើយ ។

**សទ.៥ តើនិយោជកអាចបញ្ឈប់អ្នកជំនួយការងារផ្ទះបានដែរឬទេ នៅពេលអ្នកជំនួយការងារផ្ទះមិនបានមកធ្វើការដោយការសុំច្បាប់ឈឺដោយមានប្រាក់ឈ្នួល?**

**ច**

- មិនបានទេ ។ លើកលែងតែនិយោជកបញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយសារតែគាត់ / នាងបានការប្រព្រឹត្តខុសរឿងណាមួយដោយធ្ងន់ធ្ងរ ។ បើមិនដូច្នោះទេ វានឹងត្រូវបានចាត់ជាការប្រព្រឹត្តបទល្មើសខុសរបស់និយោជក ដែលនិយោជកនឹងប្រឈមនឹងការទទួលការកាត់ទោស និងផ្តន្ទាទោសដោយផាកពិន័យ ១០០,០០០ដុល្លារហុងកុង ។
- និយោជកក៏ត្រូវផ្តល់ឱ្យអ្នកជំនួយការងារផ្ទះនូវ ៖
    - ប្រាក់ជំនួសឱ្យការជូនដំណឹង
    - ប្រាក់សរុបបន្ថែមសម្រាប់ថ្លៃសងជម្ងឺចិត្ត* ដែលគិតតាមប្រាក់ឈ្នួលសម្រាប់ចំនួនប្រាំពីរថ្ងៃ និង
    - ប្រាក់ឧបត្ថម្ភពេលមានជម្ងឺដែលគាត់ / នាងមានសិទ្ធិទទួលបាន ។
- អ្នកជំនួយការងារផ្ទះក៏អាចទាមទារ និងទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្ត នៅពេលនិយោជកបញ្ឈប់គាត់ដោយមូលហេតុមិនសមហេតុផល ឬការបញ្ឈប់មិនត្រឹមត្រូវ យោងតាមចំណុចដែលមានចែងនៅក្នុងការគំពារការងារនៃច្បាប់បទប្បញ្ញត្តិការងារ (មើលជំពូកទី ១០) ។

សម្គាល់ទី 1: លិខិតបញ្ជាក់វត្តមានមិនអាចអនុវត្តបានទៅនឹងការពិនិត្យសុខភាពរបស់ អ្នកជំនួយការងារ ផ្ទាក់ទងនឹងការពិនិត្យផ្ទៃពោះដែលបានធ្វើឡើងមុនថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2020 ។

*សម្រាប់ព័ត៌មានលម្អិតទាក់ទងនឹងការគណនាប្រាក់ឧបត្ថម្ភនៅពេលមានជម្ងឺ និងថ្លៃសងជម្ងឺចិត្ត សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ" ។ ច្បាប់ចម្លងនៃសៀវភៅណែនាំនេះ អាចរកបាននៅសាខាការិយាល័យផ្នែកទំនាក់ទំនងការងារ ឬទាញយកឯកសារនេះតាមគេហទំព័ររបស់នាយកដ្ឋានការងារ ។

# ៦ ការគាំពារនៅពេលសម្រាកមាតុភាព

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

**សង៦.១ តើមានលក្ខខណ្ឌអ្វីខ្លះដែលអ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល?**

**ច** ជំនួយការក្នុងផ្ទះជាស្ត្រីមានសិទ្ធិទទួលបានការសម្រាកមាតុភាពមានថ្ងៃឈ្នួលរយៈពេល ១៤ សប្តាហ៍ជាប់គ្នាបាន[សម្គាល់ទី 2] ប្រសិនបើពួកគេ ៖

- នាងបានបម្រើការងារយ៉ាងតិច៤០សប្តាហ៍ មុនពេលកាលបរិច្ឆេទនៃថ្ងៃច្បាប់ឈប់សម្រាកមាតុភាព
- បានផ្តល់ការជូនដំណឹងអំពីការមានផ្ទៃពោះ ហើយមានបំណងចង់សុំនិយោជករបស់នាងឈប់សម្រាកមាតុភាពក្រោយពីការមានផ្ទៃពោះត្រូវបានបញ្ជាក់ ។ ឧទាហរណ៍ដូចជាការបង្ហាញសំបុត្រពេទ្យបញ្ជាក់ពីការមានផ្ទៃពោះរបស់នាងទៅកាន់និយោជក និង
- នាងបានយកវេជ្ជបញ្ជាដែលបានបញ្ជាក់កាលបរិច្ឆេទដែលគ្រោងទុកសម្រាប់ការឆ្លងទន្លេ បើនិយោជកតម្រូវឱ្យធ្វើ ។

**សង៦.២ តើអត្រានៃច្បាប់ឈប់សម្រាកមាតុភាពដែលមានប្រាក់ឈ្នួល មានចំនួនប៉ុន្មាន? តើនៅពេលណាដែលនិយោជកគួរតែផ្តល់វាទៅឱ្យអ្នកជំនួយការងារផ្ទះ?**

**ច**

- អត្រាប្រចាំថ្ងៃនៃការគិតច្បាប់ឈប់សម្រាកមាតុភាពដែលមានប្រាក់ឈ្នួល គឺស្មើនឹង៨០ភាគរយនៃប្រាក់ឈ្នួលប្រចាំថ្ងៃគិតជាមធ្យម* របស់អ្នកជំនួយការងារផ្ទះ ។ ការផ្តល់នេះ គឺមិនត្រូវយូរជាងការផ្តល់ប្រាក់ឈ្នួលធម្មតាឡើយ ។
- និយោជក ក្រោយពីបានបង់ថ្លៃឈ្នួលនៅពេលសម្រាកមាតុភាពទាំងអស់ហើយ អាចដាក់ពាក្យទៅកាន់រដ្ឋាភិបាលដើម្បីស្នើសុំប្រាក់សំណង[សម្គាល់ទី 3] លើថ្លៃឈ្នួលពេលសម្រាក់មាតុភាពពីសប្តាហ៍ទី 11 ដល់ សប្តាហ៍ទី 14 ដែលត្រូវសងជូនវិញនៅក្រោមបទបញ្ញត្តិការងារនេះ ។ សម្រាប់ព័ត៌មានលម្អិត សូមចូលមើលព័ត៌មានដែលពាក់ព័ន្ធនឹងគម្រោងស្តីពីសំណងលើថ្លៃឈ្នួលពេលសម្រាកមាតុភាព ដែលបានចេញផ្សាយដោយក្រសួងការងារ ។

**សង៦.៣ តើនិយោជកអាចបញ្ឈប់អ្នកជំនួយការងារផ្ទះដែលមានផ្ទៃពោះបានដែរឬទេ?**

**ច**

- មិនបានទេ ។ និយោជកមិនអាចបញ្ឈប់អ្នកជំនួយការងារផ្ទះដែលមានផ្ទៃពោះ ដោយគិតចាប់ពីថ្ងៃដែលនាងបានបញ្ជាក់ថាមានផ្ទៃពោះដោយអមជាមួយនឹងវេជ្ជបញ្ជា រហូតដល់ថ្ងៃដែលនាងត្រូវត្រឡប់មកធ្វើការវិញ តាមកាលកំណត់នៃច្បាប់ឈប់សម្រាកមាតុភាព លើកលែងតែនិយោជកបញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយសារតែនាងបានប្រព្រឹត្តខុសរឿងណាមួយដោយធ្ងន់ធ្ងរ ។

- និយោជកដែលប្រព្រឹត្តផ្ទុយពីការចែងខាងលើនេះ នឹងប្រឈមមុខនឹងការកាត់ទោស និងការផ្តន្ទាទោសដោយពិន័យជាប្រាក់ ១០០,០០០ដុល្លារហុងកុង ។ និយោជកក៏ត្រូវតែផ្តល់ឱ្យអ្នកជំនួយការងារផ្ទះនូវ ៖
  - ប្រាក់ជំនួសឱ្យការជូនដំណឹង
  - ប្រាក់សរុបបន្ថែមសម្រាប់ថ្លៃសងជម្ងឺចិត្ត* ដែលគិតតាមប្រាក់ឈ្នួលសម្រាប់ចំនួនមួយខែ និង
  - ថ្លៃឈ្នួលពេលសម្រាកមាតុភាព លើកលែងតែមានការបណ្តេញចេញ ប្រសិនបើពួកគេមានសិទ្ធិទទួលបានថ្លៃឈ្នួលបែបនេះបាន ។
- អ្នកជំនួយការងារផ្ទះក៏អាចទាមទារ និងទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្ត នៅពេលនិយោជកបញ្ឈប់គាត់ដោយមូលហេតុមិនសមហេតុផល ឬការបញ្ឈប់មិនត្រឹមត្រូវ យោងតាមចំណុចដែលមានចែងនៅក្នុងការគំពារការងារនៃច្បាប់បទប្បញ្ញត្តិការងារ (មើលជំពូកទី ១០) ។

សម្គាល់ទី 2: ជំនួយការក្នុងផ្ទះជាស្ត្រីដែលការឆ្លងទន្លេរបស់ពួកគេកើតឡើង នៅមុនថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2020 មានសិទ្ធិទទួលបានការសម្រាកមាតុភាពមានថ្លៃឈ្នួលរយៈពេល ១០ សប្តាហ៍ ។

សម្គាល់ទី 3: គម្រោងស្តីពីសំណងលើថ្លៃឈ្នួលពេលសម្រាកមាតុភាពគឺជាគម្រោងរដ្ឋបាលរបស់រដ្ឋាភិបាល ។

*សម្រាប់ព័ត៌មានលម្អិតទាក់ទងនឹងការគណនាប្រាក់សម្រាប់ច្បាប់ឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល និងថ្លៃសងជម្ងឺចិត្ត សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ" ។ ច្បាប់ចម្លងនៃសៀវភៅណែនាំនេះ អាចរកបាននៅសាខាការិយាល័យផ្នែកទំនាក់ទំនងការងារ ឬទាញយកឯកសារនេះតាមគេហទំព័ររបស់នាយកដ្ឋានការងារ ។

# ៧ ច្បាប់ឈប់សម្រាកបិតុភាព

## សម្រាប់និយោជក និងអ្នកជួយធ្វើការផ្ទះ

**សព.១ តើមានលក្ខខណ្ឌអ្វីខ្លះដែលអ្នកជួយធ្វើការផ្ទះមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួល?**

**ច** អ្នកជួយធ្វើការផ្ទះជាបុរសអាចមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួលចំនួនប្រាំថ្ងៃនៅពេលប្រពន្ធ / ដៃគូររបស់គាត់ឆ្លងទន្លេ ប្រសិនបើគាត់ -

- បានបម្រើការងារតិចបំផុត ៤០ សប្តាហ៍ មុនថ្ងៃដែលសុំច្បាប់ឈប់សម្រាកបិតុភាព
- បានជូនដំណឹងទៅឱ្យនិយោជករបស់គាត់ និង
- បានផ្តល់នូវឯកសារដែលចាំបាច់ដល់និយោជកក្នុងកំឡុងពេលដូចខាងក្រោម (កំឡុងពេលណាមួយដែលដល់ពេលកំណត់ដំបូង) -
  - ១២ខែបន្ទាប់ពីថ្ងៃដំបូងនៃច្បាប់ឈប់សម្រាកបិតុភាពដែលបានសុំ ឬ
  - ក្នុកំឡុងពេល៦ខែបន្ទាប់ពីការឈប់ធ្វើការ ប្រសិនបើគាត់សុំឈប់ធ្វើការ ។

**សព.២ តើអ្នកជួយធ្វើការផ្ទះគួរជូនដំណឹងដល់និយោជករបស់គាត់ដោយរបៀបណា ដើម្បីសុំច្បាប់ឈប់សម្រាកបិតុភាព?**

**ច**
- អ្នកជួយធ្វើការផ្ទះត្រូវជូនដំណឹងដល់និយោជករបស់គាត ពីការសុំច្បាប់ឈប់សម្រាកបិតុភាពយ៉ាងតិច៣ខែមុនកាលបរិច្ឆេទដែលគ្រោងទុកថាកូនរបស់គាត់នឹងកើត (ថ្ងៃជាក់លាក់នៃច្បាប់ឈប់សម្រាកមិនកំណត់ចំពោះករណីនេះ) និងមុនថ្ងៃដែលគាត់សុំច្បាប់ឈប់សម្រាកបិតុភាព ។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះមិនបានជូនដំណឹង៣ខែមុនទៅដល់និយោជក ដូចបានចែងខាងលើនោះទេ គាត់ត្រូវតែជូនដំណឹងដល់និយោជកពីកាលបរិច្ឆេទនៃច្បាប់ឈប់សម្រាកបិតុភាពរបស់គាត់យ៉ាងតិច៥ថ្ងៃមុនកាលបរិច្ឆេទនោះ ។

**សព.៣ តើនៅពេលណាដែលខ្ញុំអាចទទួលបានច្បាប់ឈប់សម្រាកបិតុភាព?**

**ច**
- អ្នកជួយធ្វើការផ្ទះអាចទទួលបានច្បាប់ឈប់សម្រាកបិតុភាពបាននៅថ្ងៃណាមួយដែលស្ថិតនៅក្នុងកំឡុងពេលពី៤សប្តាហ៍មុនកាលបរិច្ឆេទដែលគ្រោងទុកថាកូនរបស់គាត់នឹងកើត ទៅ១៤សប្តាហ៍នៃការចាប់ផ្តើមដឹងពីថ្ងៃជាក់លាក់ដែលកូនគាត់នឹងកើត[សម្គាល់ទី 4] ។
- និយោជកអាចផ្តល់ច្បាប់ឈប់សម្រាកបិតុភាពចំនួនប្រាំថ្ងៃ ដោប្រាំថ្ងៃជាប់គ្នាតែម្តង ឬដោយរំលងថ្ងៃពីគ្នា ។

**សព.៤ តើមានឯកសារអ្វីខ្លះដែលអ្នកជួយធ្វើការផ្ទះត្រូវប្រគល់ជូននិយោជក នៅពេលសុំច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួល?**

**ច**

- សំបុត្រកំណើតរបស់ទារកដែលរួមមានឈ្មោះរបស់អ្នកជួយធ្វើការផ្ទះក្នុងនាមជាឪពុករបស់ទារកនោះ ។
- ក្នុងករណីដែលទារកបានស្លាប់នៅពេលកើត ឬស្លាប់បន្ទាប់ពីកើត ហើយគ្មានការចេញសំបុត្រកំណើតដែលទាក់ទងនឹងទារក អ្នកជួយធ្វើការផ្ទះត្រូវតែយកវេជ្ជបញ្ជាដែលបញ្ជាក់ពីការសម្រាលកូននោះឱ្យនិយោជកដើម្បីបញ្ជាក់ ។

**សព.៥ តើអត្រានៃច្បាប់ឈប់សម្រាកបិតុភាពដែលមានប្រាក់ឈ្នួល មានចំនួនប៉ុន្មាន? តើនៅពេលណាដែលនិយោជកគួរតែផ្តល់វាទៅឱ្យអ្នកជួយធ្វើការផ្ទះ?**

**ច**

- អត្រាប្រចាំថ្ងៃនៃការគិតច្បាប់ឈប់សម្រាកមាតុភាពដែលមានប្រាក់ឈ្នួល គឺស្មើនឹងបួនភាគប្រាំនៃប្រាក់ឈ្នួលប្រចាំថ្ងៃដែលគិតជាមធ្យម របស់អ្នកជួយធ្វើការផ្ទះ ដែលបានបំពេញការងារអស់រយៈពេល១២ខែ មុនថ្ងៃឈប់សម្រាកបិតុភាព*។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះបានផ្តល់ឯកសារដែលចាំបាច់ទៅឲ្យនិយោជកមុនថ្ងៃឈប់សម្រាកបិតុភាពនោះ និយោជកត្រូវតែផ្តល់ប្រាក់សម្រាប់ច្បាប់សម្រាកបិតុភាពជូនគាត់ –
  - ដោយមិនយឺតជាងថ្ងៃ ដែលគាត់ទទួលបានប្រាក់ឈ្នួលធម្មតានៅខែបន្ទាប់ពីថ្ងៃដែលគាត់ឈប់សម្រាប់បិតុភាពនោះឡើយ ឬ
  - កំឡុងពេល៧ថ្ងៃបន្ទាប់ពីការឈប់ធ្វើការ ក្នុងករណីដែលគាត់សុំឈប់ធ្វើការ ។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះបានផ្តល់ឯកសារដែលចាំបាច់ទៅឲ្យនិយោជក ក្រោយថ្ងៃឈប់សម្រាកបិតុភាពនោះ និយោជកត្រូវតែផ្តល់ប្រាក់សម្រាប់ច្បាប់សម្រាកបិតុភាពជូនគាត់ –
  - ដោយមិនយឺតជាងថ្ងៃដែលគាត់ទទួលបានប្រាក់ឈ្នួលនៅខែបន្ទាប់ ក្រោយពីឯកសារត្រូវបានប្រគល់ជូននោះឡើយ ឬ
  - កំឡុងពេល៧ថ្ងៃបន្ទាប់ពីការឈប់ធ្វើការ ក្នុងករណីដែលគាត់សុំឈប់ធ្វើការ ។

សម្គាល់ទី 4: ប្រសិនបើទារកបានកើត នៅមុនថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2020 វាមានរយៈពេលរហូតដល់ ១០ សប្តាហ៍ដោយចាប់ផ្តើមពីកាលបរិច្ឆេទជាក់លាក់នៃការកើតរបស់ទារករូបនេះ ។

*សម្រាប់ព័ត៌មានលម្អិតអំពីការគណនាប្រាក់ថ្លៃឈប់សម្រាកបិតុភាព សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ" ។ ច្បាប់ចម្លងនៃសៀវភៅណែនាំនេះ អាចរកបាននៅសាខាការិយាល័យផ្នែកទំនាក់ទំនងការងារ ឬទាញយកឯកសារនេះតាមគេហទំព័ររបស់នាយកដ្ឋានការងារ ។

# ៧ ច្បាប់ឈប់សម្រាកបិតុភាព

## សម្រាប់និយោជក និងអ្នកជួយធ្វើការផ្ទះ

**សព.១ តើមានលក្ខខណ្ឌអ្វីខ្លះដែលអ្នកជួយធ្វើការផ្ទះមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួល?**

**ច** អ្នកជួយធ្វើការផ្ទះជាបុរសអាចមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួលចំនួនប្រាំថ្ងៃ នៅពេលប្រពន្ធ / ដៃគូររបស់គាត់ឆ្លងទន្លេ ប្រសិនបើគាត់ -

- បានបម្រើការងារតិចបំផុត ៤០ សប្តាហ៍ មុនថ្ងៃដែលសុំច្បាប់ឈប់សម្រាកបិតុភាព
- បានជូនដំណឹងទៅឱ្យនិយោជករបស់គាត់ និង
- បានផ្តល់នូវឯកសារដែលចាំបាច់ដល់និយោជកក្នុងកំឡុងពេលដូចខាងក្រោម (កំឡុងពេលណាមួយដែលដល់ពេលកំណត់ដំបូង) -
  - ១២ខែបន្ទាប់ពីថ្ងៃដំបូងនៃច្បាប់ឈប់សម្រាកបិតុភាពដែលបានសុំ ឬ
  - ក្នុកំឡុងពេល៦ខែបន្ទាប់ពីការឈប់ធ្វើការ ប្រសិនបើគាត់សុំឈប់ធ្វើការ ។

**សព.២ តើអ្នកជួយធ្វើការផ្ទះគួរជូនដំណឹងដល់និយោជករបស់គាត់ដោយរបៀបណា ដើម្បីសុំច្បាប់ឈប់សម្រាកបិតុភាព?**

**ច**
- អ្នកជួយធ្វើការផ្ទះត្រូវជូនដំណឹងដល់និយោជករបស់គាត ពីការសុំច្បាប់ឈប់សម្រាកបិតុភាពយ៉ាងតិច៣ខែមុនកាលបរិច្ឆេទដែលគ្រោងទុកថាកូនរបស់គាត់នឹងកើត (ថ្ងៃជាក់លាក់នៃច្បាប់ឈប់សម្រាកមិនកំណត់ចំពោះករណីនេះ) និងមុនថ្ងៃដែលគាត់សុំច្បាប់ឈប់សម្រាកបិតុភាព ។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះមិនបានជូនដំណឹង៣ខែមុនទៅដល់និយោជក ដូចបានចែងខាងលើនោះទេ គាត់ត្រូវតែជូនដំណឹងដល់និយោជកពីកាលបរិច្ឆេទនៃច្បាប់ឈប់សម្រាកបិតុភាពរបស់គាត់យ៉ាងតិច៥ថ្ងៃមុនកាលបរិច្ឆេទនោះ ។

**សព.៣ តើនៅពេលណាដែលខ្ញុំអាចទទួលបានច្បាប់ឈប់សម្រាកបិតុភាព?**

**ច**
- អ្នកជួយធ្វើការផ្ទះអាចទទួលបានច្បាប់ឈប់សម្រាកបិតុភាពបាននៅថ្ងៃណាមួយដែលស្ថិតនៅក្នុងកំឡុងពេលពី៤សប្តាហ៍មុនកាលបរិច្ឆេទដែលគ្រោងទុកថាកូនរបស់គាត់នឹងកើត ទៅ១៤សប្តាហ៍នៃការចាប់ផ្តើមដឹងពីថ្ងៃជាក់លាក់ដែលកូនគាត់នឹងកើត[សម្គាល់ទី 4] ។
- និយោជកអាចផ្តល់ច្បាប់ឈប់សម្រាកបិតុភាពចំនួនប្រាំថ្ងៃ ដោប្រាំថ្ងៃជាប់គ្នាតែម្តង ឬដោយរំលងថ្ងៃពីគ្នា ។

**សព.៤ តើមានឯកសារអ្វីខ្លះដែលអ្នកជួយធ្វើការផ្ទះត្រូវប្រគល់ជូននិយោជក នៅពេលសុំច្បាប់ឈប់សម្រាកបិតុភាពដោយមានប្រាក់ឈ្នួល?**

**ច**

- សំបុត្រកំណើតរបស់ទារកដែលរួមមានឈ្មោះរបស់អ្នកជួយធ្វើការផ្ទះក្នុងនាមជាឪពុករបស់ទារកនោះ ។
- ក្នុងករណីដែលទារកបានស្លាប់នៅពេលកើត ឬស្លាប់បន្ទាប់ពីកើត ហើយគ្មានការចេញសំបុត្រកំណើតដែលទាក់ទងនឹងទារក អ្នកជួយធ្វើការផ្ទះត្រូវតែយកវេជ្ជបញ្ជាដែលបញ្ជាក់ពីការសម្រាលកូននោះឱ្យនិយោជកដើម្បីបញ្ជាក់ ។

**សព.៥ តើអត្រានៃច្បាប់ឈប់សម្រាកបិតុភាពដែលមានប្រាក់ឈ្នួល មានចំនួនប៉ុន្មាន? តើនៅពេលណាដែលនិយោជកគួរតែផ្តល់វាទៅឱ្យអ្នកជួយធ្វើការផ្ទះ?**

**ច**

- អត្រាប្រចាំថ្ងៃនៃការគិតច្បាប់ឈប់សម្រាកមាតុភាពដែលមានប្រាក់ឈ្នួល គឺស្មើនឹងបួនភាគប្រាំនៃប្រាក់ឈ្នួលប្រចាំថ្ងៃដែលគិតជាមធ្យម របស់អ្នកជួយធ្វើការផ្ទះ ដែលបានបំពេញការងារអស់រយៈពេល១២ខែ មុនថ្ងៃឈប់សម្រាកបិតុភាព*។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះបានផ្តល់ឯកសារដែលចាំបាច់ទៅឲ្យនិយោជកមុនថ្ងៃឈប់សម្រាកបិតុភាពនោះ និយោជកត្រូវតែផ្តល់ប្រាក់សម្រាប់ច្បាប់សម្រាកបិតុភាពជូនគាត់ –
  - ដោយមិនយឺតជាងថ្ងៃ ដែលគាត់ទទួលបានប្រាក់ឈ្នួលធម្មតានៅខែបន្ទាប់ពីថ្ងៃដែលគាត់ឈប់សម្រាប់បិតុភាពនោះឡើយ ឬ
  - កំឡុងពេល៧ថ្ងៃបន្ទាប់ពីការឈប់ធ្វើការ ក្នុងករណីដែលគាត់សុំឈប់ធ្វើការ ។
- ប្រសិនបើអ្នកជួយធ្វើការផ្ទះបានផ្តល់ឯកសារដែលចាំបាច់ទៅឲ្យនិយោជក ក្រោយថ្ងៃឈប់សម្រាកបិតុភាពនោះ និយោជកត្រូវតែផ្តល់ប្រាក់សម្រាប់ច្បាប់សម្រាកបិតុភាពជូនគាត់ –
  - ដោយមិនយឺតជាងថ្ងៃដែលគាត់ទទួលបានប្រាក់ឈ្នួលនៅខែបន្ទាប់ ក្រោយពីឯកសារត្រូវបានប្រគល់ជូននោះឡើយ ឬ
  - កំឡុងពេល៧ថ្ងៃបន្ទាប់ពីការឈប់ធ្វើការ ក្នុងករណីដែលគាត់សុំឈប់ធ្វើការ ។

សម្គាល់ទី 4: ប្រសិនបើទារកបានកើត នៅមុនថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2020 វាមានរយៈពេលរហូតដល់ ១០ សប្តាហ៍ដោយចាប់ផ្តើមពីកាលបរិច្ឆេទជាក់លាក់នៃការកើតរបស់ទារករូបនេះ ។

*សម្រាប់ព័ត៌មានលម្អិតអំពីការគណនាប្រាក់ថ្លៃឈប់សម្រាកបិតុភាព សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ" ។ ច្បាប់ចម្លងនៃសៀវភៅណែនាំនេះ អាចរកបាននៅសាខាការិយាល័យផ្នែកទំនាក់ទំនងការងារ ឬទាញយកឯកសារនេះតាមគេហទំព័ររបស់នាយកដ្ឋានការងារ ។

# ៨ ការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

### សផ.១ តើនិយោជក ឬអ្នកជំនួយការងារផ្ទះអាចបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់បានដែរឬទេ?

**ច** បាន ភាគីម្ខាងអាចបញ្ចប់កិច្ចសន្យាមុនពេលកំណត់បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងតិចមួយខែមុន ឬផ្តល់ជាប្រាក់ឈ្នួលជំនួសសម្រាប់រយៈពេលមួយខែទៅឲ្យភាគីម្ខាងទៀត ។ គំរូលិខិតបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ដោយអ្នកជំនួយការងារផ្ទះមកពីបរទេស (FDH) ឬដោយនិយោជក មាននៅឧបសម្ព័ន្ធទី IVក និងឧបសម្ព័ន្ធទី IVខ ។

### សផ.២ តើខ្ញុំគួរធ្វើដូចម្តេចនៅពេលកិច្ចសន្យាការងារត្រូវបានបញ្ចប់មុនពេលកំណត់ ឬតាមកាលកំណត់?

**ច**

| សម្រាប់និយោជក | សម្រាប់អ្នកជំនួយការងារផ្ទះ |
| --- | --- |
| • អ្នកគួរតែផ្តល់ប្រាក់ឈ្នួលបង្គ្រប់ដែលមិនទាន់បានផ្តល់ឱ្យ និងប្រាក់សរុបផ្សេងទៀតដល់អ្នកជំនួយការងារផ្ទះអ្នក តាមរយៈធនាគារប្រសិនជាការស្នើសុំរបស់អ្នកជំនួយការងារផ្ទះ និងរក្សាទុកនូវវិក័យបត្ររាល់ការផ្តល់ជូនទាំងអស់ ។<br><br>• អ្នកត្រូវជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យានេះជាលាយលក្ខណ៍អក្សរ ដល់ការិយាល័យផ្នែកអ្នកជំនួយការងារផ្ទះមកពីបរទេសនៃនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងកំឡុងពេលប្រាំពីរថ្ងៃនៃកាលបរិច្ឆេទដែលបញ្ចប់កិច្ចសន្យា ។ វាមិនចាំបាច់ក្នុងការជូនដំណឹងដល់នាយកដ្ឋានការងារឡើយ ។ | • អ្នកគួរពិនិត្យមើលគណនី ឬប្រាក់ដែលត្រូវទទួលបាន ជាមួយនិយោជករបស់អ្នកជាមុនសិន និងត្រូវប្រាកដថាអ្នកបានទទួលប្រាក់សរុបទាំងអស់ មុនពេលដែលអ្នកចុះហត្ថលេខាលើវិក័យបត្រណាមួយដែលផ្តល់ដោយនិយោជក ។<br><br>• អ្នកត្រូវជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យានេះជាលាយលក្ខណ៍អក្សរ ដល់ការិយាល័យផ្នែកអ្នកជំនួយការងារផ្ទះមកពីបរទេសនៃនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងកំឡុងពេលប្រាំពីរថ្ងៃនៃកាលបរិច្ឆេទដែលបញ្ចប់កិច្ចសន្យា ។ វាមិនចាំបាច់ក្នុងការជូនដំណឹងដល់នាយកដ្ឋានការងារឡើយ ។ |

## សឆ.៣ តើនិយោជក ឬអ្នកជំនួយការងារផ្ទះអាចបញ្ចប់កិច្ចសន្យាមុនពេលកំណត់ដោយមិនមានការជូនដំណឹងមុន ឬមិនបានផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹងបានដែរឬទេ?

**ច** ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ដោយមិនមានការជូនដំណឹងមុន ឬមិនបានផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹង អាចធ្វើបានតែនៅពេលដែលមានករណីពិសេសមួយចំនួនកើតឡើងតែប៉ុណ្ណោះ ។

| សម្រាប់និយោជក | សម្រាប់អ្នកជំនួយការងារផ្ទះ |
| --- | --- |
| អ្នកអាចបញ្ឈប់អ្នកជំនួយការងារផ្ទះអ្នក ដោយមិនចាំបាច់ជូនដំណឹង ឬមិនផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹងបាន ក្នុងករណីអ្នកជំនួយការងារផ្ទះអ្នកបានប្រព្រឹត្តទង្វើពាក់ព័ន្ធនឹងការងាររបស់គាត់ ដូចខាងក្រោម ៖<br>• មានចេតនាមិនគោរពច្បាប់ និងបទបញ្ជាដែលសមហេតុផលពីនិយោជក<br>• ប្រព្រឹត្តរឿងខុសឆ្គងណាមួយដោយខ្លួនគាត់ / ខ្លួននាងផ្ទាល់<br>• បានប្រព្រឹត្តខុសដោយក្លែងបន្លំ ឬមានភាពមិនស្មោះត្រង់ ឬ<br>• មានទម្លាប់ធ្វេសការ ឬបំពេញភារកិច្ចរបស់គាត់ / នាងដោយធ្វេសប្រហែស ។ | អ្នកអាចបញ្ចប់កិច្ចសន្យាការងាររបស់អ្នកបានដោយមិនចាំបាច់ ជូនដំណឹង ឬមិនសងប្រាក់ជំនួសដល់ការជូនដំណឹងបាន ក្នុងករណីដែល ៖<br>• អ្នកទទួលរងការបំពានផ្លូវកាយដោយការប្រើអំពើហិង្សា ឬដោយសាររោគជម្ងឺ<br>• អ្នកបានប្រឈមនឹងការមិនឱ្យតម្លៃ ឬការប្រមាថពីនិយោជករបស់អ្នក ឬ<br>• អ្នកបានចូលបម្រើការងារមិនដល់ ៥ ឆ្នាំ ហើយអ្នកត្រូវបានបញ្ជាក់ដោយគ្រូពេទ្យដែលបានចុះបញ្ជី ឬគ្រូចិនសែដែលបញ្ជាក់ថាអ្នកមិនមានកាយសម្បទាស័ក្តិសមសម្រាប់ការងារបច្ចុប្បន្ន ។ |

## សឆ.៤ តើខ្ញុំគួរវិភាគថ្លឹងថ្លែងអ្វីខ្លះ មុនសម្រេចចិត្តបញ្ចប់កិច្ចសន្យាមុនពេលកំណត់ដោយពុំមានការជូនដំណឹងមុន?

- ការបញ្ចប់កិច្ចសន្យាដោយពុំមានការជូនដំណឹង ជាធម្មតា កើតឡើងពីការខ្វែងគំនិតគ្នារវាងនិយោជក និងអ្នកជំនួយការងារផ្ទះ ។ ក្នុងកំឡុងពេលនៃការឈ្លោះប្រកែកគ្នាដ៏ក្តៅគគុកនេះ វាអាចនឹងបង្កឲ្យវិវាទនេះកាន់តែខ្លាំងឡើង ហើយភាគីនីមួយៗនឹងជឿជាក់ថា វាសមហេតុផលដែលធ្វើឱ្យគាត់ / នាងឈានដល់ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ឬសម្រេចថាកិច្ចសន្យានោះបានបញ្ចប់ ។ ទង្វើ ឬការសម្រេចចិត្តបែបនេះជារឿយៗគឺចាត់ទុកជាការគិតដែលខ្វះវិចារណញ្ញាណ ឬការត្រិះរិះពិចារណា ។ ដោយសារតែ ជាធម្មតា ពុំមានសាក្សីឯករាជ្យណាមួយដែលប្រឡូកនៅក្នុងមជ្ឈដ្ឋាននៃវិវាទកិច្ចការផ្ទះនោះទេ ដូចនេះវាអាចនឹងមានការលំបាកក្នុងការស្វែងរកមូលហេតុ ដែលនាំឲ្យមានវិវាទ និងពិបាកក្នុងការសម្រេចថាតើសកម្មភាពដែលបានកើតឡើងនោះមានហេតុផលត្រឹមត្រូវគ្រប់គ្រាន់ហើយឬនៅ ។

- វិធីដែលល្អបំផុតក្នុងការដោះស្រាយវិវាទការងារ គឺតម្រូវឲ្យភាគីទាំងពីរនិយាយពីហេតុការណ៍គ្រប់យ៉ាងដែលបានកើតឡើងចេញមក ។ អ្នកគួរតែមានចិត្តសន្ដោស និងអត់ធ្មត់ចំពោះគ្នាទៅវិញទៅមក ដើម្បីដឹង ឬបែងចែកភាពខុសគ្នារវាងអ្នកទាំងពីរ ។ វិវាទភាគច្រើនអាចដោះស្រាយបាន ដោយពុំចាំបាច់ដល់ថ្នាក់ចាត់វិធានការណ៍កម្រិតធ្ងន់ ។

- អ្នកអាចសម្រេចចិត្តក្នុងការបញ្ចប់កិច្ចសន្យាដោយពុំមានការជូនដំណឹងមុន លុះត្រាតែវាស្ថិតនៅក្នុងករណីពិសេសតែប៉ុណ្ណោះ ។ ប្រសិនបើអ្នកពិតជាត្រូវធ្វើវាដូច្នោះមែន អ្នកគួរតែប្រាកដថាអ្នកមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ ឬអះអាងទៅលើសំណុំរឿងរបស់អ្នក ។ បើពុំដូច្នោះទេ អ្នកអាចប្រឈមមុខនឹងការប្ដឹងទាមទារពីភាគីម្ខាងទៀតវិញ ។

### សខ៨.៥ តើខ្ញុំគួរធ្វើដូចម្ដេចប្រសិនបើអ្នកជំនួយការងារផ្ទះខ្ញុំបានចាកចេញដោយពុំមានការជូនដំណឹង ឬសងប្រាក់ជំនួសឲ្យការមិនជូនដំណឹងដល់ខ្ញុំ?

### ឬ

### តើខ្ញុំគួរធ្វើអ្វីខ្លះប្រសិនបើនិយោជករបស់ខ្ញុំបញ្ឈប់ខ្ញុំដោយពុំមានការជូនដំណឹង ឬផ្ដល់ប្រាក់ជំនួសឲ្យការមិនជូនដំណឹងដល់ខ្ញុំ?

**ច**

- អ្នកគួរជូនដំណឹងដល់ការិយាល័យផ្នែកអ្នកជំនួយការងារផ្ទះមកពីបរទេស នៃនាយកដ្ឋានអន្តោប្រវេសន៍ ប្រសិនបើអ្នកគិតថាការបញ្ចប់កិច្ចសន្យាមុនពេលកំណត់នោះធ្វើឡើងដោយឯកតោភាគីពីភាគីម្ខាងទៀត ។ ចំពោះនិយោជក ប្រសិនបើអ្នកមិនបានដឹងពីទីតាំងកន្លែងស្នាក់នៅរបស់អ្នកជំនួយការងារផ្ទះអ្នកនោះទេ អ្នកក៏អាចរាយការណ៍ពីករណីបាត់ខ្លួនរបស់គាត់ / នាងទៅកាន់ប៉ូលីសផងដែរ ។

- ប្រសិនបើអ្នកគិតថា ភាគីម្ខាងទៀតពុំមានសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាដោយពុំមានការជូនដំណឹងទេនោះ ហើយអ្នកមានបំណងទាមទារប្រាក់ជំនួសដោយការមិនជូនដំណឹងនោះ អ្នកគួរតែទៅកាន់សាខាការិយាល័យផ្នែកទំនាក់ទំនងការងារនៃនាយកដ្ឋានការងារផ្ទាល់ដោយមិនត្រូវបង្អង់ពេលវេលានោះឡើយ ។ ការិយាល័យផ្នែកនេះនឹងជួយអ្នកដោះស្រាយក្នុងការទាមទារនោះ តាមរយៈការសម្របសម្រួលផ្សះផ្សារ (មើលជំពូកទី ១២) ។

- ប៉ុន្តែអ្នកក៏អាចច្រានចោលលក្ខខណ្ឌដែលតម្រូវឱ្យមានការជូនដំណឹងដោយសមស្របពីភាគីម្ខាងទៀតដែរ ។

## សឲ.៦ តើមានអ្វីខ្លះដែលខ្ញុំត្រូវផ្តល់អ្នកជំនួយការងារផ្ទះខ្ញុំ នៅពេលបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ឬតាមកាលកំណត់?

**ច**

- ការផ្តល់ជូនសម្រាប់អ្នកជំនួយការងារផ្ទះអ្នក នៅពេលបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ឬតាមកាលកំណត់ គឺអាស្រ័យលើកត្តាមួយចំនួន ដូចជារយៈពេលនៃការបម្រើការងាររបស់គាត់ / នាង និងមូលហេតុនៃការបញ្ចប់កិច្ចសន្យា ។ ប៉ុន្តែជាធម្មតា ការផ្តល់ជូននៅពេលបញ្ចប់កិច្ចសន្យានោះ រួមមាន ៖
  - ផ្តល់ប្រាក់ឈ្នួលបង្គ្រប់ដែលមិនទាន់បានផ្តល់ឱ្យ
  - ផ្តល់ជាការបង់សំណងជំនួសឱ្យការមិនបានជូនដំណឹង ក្នុងករណីមិនបានជូនដំណឹង
  - ផ្តល់ប្រាក់ដែលគិតពីការសល់ច្បាប់ប្រចាំឆ្នាំ ដែលអ្នកជំនួយការងារផ្ទះមិនបានសុំ និងគិតតាមសមាមាត្រនៃច្បាប់សរុបសម្រាប់ច្បាប់ដែលនៅសល់ក្នុងពេលបញ្ឈប់នោះ (មើលជំពូកទី ៤)
  - ផ្តល់ប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះជំនួសដល់ការមិនបានបន្តកិច្ចសន្យា ឬប្រាក់ដែលទទួលក្រោយឈប់ធ្វើការ និង (មើលជំពូកទី ៩)
  - ផ្តល់ប្រាក់លើការចំណាយដទៃទៀតដល់អ្នកជំនួយការងារផ្ទះដោយយោងតាមកិច្ចសន្យាការងារ ដូចជាការត្រឡប់មកមាតុភូមិវិញដោយឥតគិតថ្លៃ ការហូបចុក និងថ្លៃធ្វើដំណើរជាដើម (មើលជំពូកទី ១១) ។
- អ្នកគួរតែរក្សាទុកវិក័យបត្រលើការចំណាយទាំងនោះ ។ គំរូនៃវិក័យបត្រសម្រាប់ការចំណាយនៅពេលបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ / តាមកាលកំណត់ មាននៅឧបសម្ព័ន្ធទី V ។

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

**សទ៩.១ តើមូលហេតុ ឬលក្ខខណ្ឌអ្វីខ្លះដែលនិយោជកគួរតែផ្តល់ប្រាក់សំណងសម្រាប់ការបញ្ឈប់ពីការងារ ដល់អ្នកជំនួយការងារផ្ទះ?**

**ច** និយោជកគួរតែផ្តល់ប្រាក់សំណងសម្រាប់ការបញ្ឈប់ពីការងារ ដល់អ្នកជំនួយការងារផ្ទះក្នុងករណីគាត់ / នាង ៖

- ត្រូវបាននិយោជកបញ្ឈប់ ឬមិនបានបន្ត*កិច្ចសន្យាដែលមានថិរវេលាកំណត់ ដោយសារតែមូលហេតុមិនត្រូវការគាត់ / នាងឱ្យធ្វើការបន្តទៀត និង
- បានធ្វើការជាមួយនិយោជកតែម្នាក់លើសពី២៤ខែ មុនពេលដែលត្រូវបានបញ្ឈប់ ។

**សទ៩.២ តើមូលហេតុ ឬលក្ខខណ្ឌអ្វីខ្លះដែលនិយោជកគួរតែផ្តល់ប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះធ្វើការយូរឆ្នាំ?**

**ច** និយោជកគួរតែផ្តល់ប្រាក់ សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះធ្វើការយូរឆ្នាំ ក្នុងករណីគាត់ / នាងបានបម្រើការងារជាបន្តបន្ទាប់ក្នុងរយៈពេលយ៉ាងតិចប្រាំឆ្នាំ និង ៖

- ត្រូវបានបណ្តេញចេញ ឬកិច្ចសន្យារយៈពេលថេរមិនបានបន្តទេ * ដោយហេតុផលក្រៅពីការបណ្តេញចេញដោយសារតែកំហុសធ្ងន់ធ្ងររបស់គាត់ ឬចំនួនលើសតម្រូវការ
- មានការបញ្ជាក់ពីគ្រូពេទ្យដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ឬគ្រូពេទ្យជនជាតិចិនដែលមានអាជ្ញាប័ណ្ណ ទៅលើសុខភាពរាងកាយរបស់គាត់/នាងដែលមិនស័ក្តិសមជាមួយនឹងការងារដែលកំពុងធ្វើ ហើយគាត់/នាងបានសុំឈប់ពីការងារ
- មានអាយុចាប់ពី៦៥ឆ្នាំឡើងទៅ ហើយគាត់ / នាងបានសុំឈប់ពីការងារ ឬ
- បានទទួលមរណភាពនៅកំឡុងពេលបម្រើការងារ ។

**សទ៩.៣ តើអ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានប្រាក់ដែលផ្តល់ឱ្យក្រោយឈប់ធ្វើការ និងប្រាក់សម្រាប់បញ្ឈប់គាត់ ដោយជំនួសការមិនបានបន្តកិច្ចសន្យា ក្នុងពេលតែមួយបានដែរឬទេ?**

**ច** មិនបានទេ ។ អ្នកជំនួយការងារផ្ទះមិនអាចទទួលយកប្រាក់ដែលផ្តល់ឱ្យក្រោយឈប់ធ្វើការ និងប្រាក់សម្រាប់បញ្ឈប់គាត់ ដោយជំនួសការមិនបានបន្តកិច្ចសន្យា ក្នុងពេលតែមួយបាននោះទេ ។ អ្នកជំនួយការងារផ្ទះមានសិទ្ធិទទួលបានតែប្រាក់ដែលផ្តល់ឱ្យក្រោយឈប់ធ្វើការ ប៉ុន្តែពុំមានសិទ្ធិទទួលបានប្រាក់សម្រាប់បញ្ឈប់គាត់ ដោយជំនួសការមិនបានបន្តកិច្ចសន្យានោះឡើយ នៅពេលគាត់ត្រូវបាននិយោជកបញ្ឈប់ដោយសារលែងត្រូវការឱ្យធ្វើការបន្ត ។

## សទ៩.៤ តើប្រាក់ដែលផ្ដល់ឱ្យក្រោយឈប់ធ្វើការ និងប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយជំនួសការមិនបានបន្តកិច្ចសន្យា ត្រូវបានគណនាយ៉ាងដូចម្ដេច?

**ច** រូបមន្តខាងក្រោម គឺសម្រាប់គណនាទាំងប្រាក់ដែលផ្ដល់ឱ្យក្រោយឈប់ធ្វើការ និងប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយជំនួសការមិនបានបន្តកិច្ចសន្យា ៖

[(ប្រាក់ឈ្នួលប្រចាំខែ x ២/៣) x ចំនួនឆ្នាំដែលបានធ្វើការ សម្គាល់]
សម្គាល់ រយៈពេលនៃការធ្វើការងារដែលមិនទាន់បានបញ្ចប់ក្នុងមួយឆ្នាំដែលបានគណនាតាមសមាមាត្រ ។

*(សម្រាប់លម្អិតទាក់ទងនឹងការគណនា សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ" ។)*

*ប្រសិនបើនិយោជកបានស្នើនូវការបន្តសុពលភាពនៃកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ឬយកអ្នកជំនួយការងារផ្ទះដដែលឲ្យចូលបម្រើការងារសារជាថ្មីទៅតាមកិច្ចសន្យាថ្មី ក្នុងរយៈពេលយ៉ាងតិចប្រាំពីរថ្ងៃមុនថ្ងៃដែលបញ្ឈប់មុនពេលកំណត់ / តាមកាលកំណត់នៃកិច្ចសន្យាដែលមានថិរវេលាជាក់លាក់ចំពោះប្រាក់ដែលផ្ដល់ឱ្យក្រោយឈប់ធ្វើការ និងក្នុងរយៈពេលយ៉ាងតិចប្រាំពីរថ្ងៃមុនពេលកាលកំណត់នៃការចប់កិច្ចសន្យាដែលមានថិរវេលាជាក់លាក់ចំពោះប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយជំនួសការមិនបានបន្តកិច្ចសន្យា ប៉ុន្តែអ្នកជំនួយការងារផ្ទះបានបដិសេធមិនបន្តធ្វើការជាមួយទៀតដោយពុំមានហេតុផលសមស្រប នោះគាត់ / នាងពុំមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលលក្ខខណ្ឌទាំងនេះឡើយ ។

# ១០ ការគាំពារការងារ

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

**ស១០.១ តើមានមូលហេតុ ឬលក្ខខណ្ឌអ្វីខ្លះដែលអ្នកជំនួយការងារផ្ទះអាចធ្វើការទាមទារ ឬទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្តពីនិយោជករបស់ គាត់/នាង សម្រាប់ការបញ្ឈប់គាត់ / នាងដោយមូលហេតុមិនសមហេតុផល?**

**ច**

- ផ្នែកការគាំពារការងារនៃច្បាប់បទប្បញ្ញត្តិការងារ មានគោលបំណងក្នុងការណែនាំនិយោជកមិនឱ្យបញ្ឈប់និយោជិតរបស់ខ្លួន ដើម្បីគេចវេសពីទំនួលខុសត្រូវនានារបស់និយោជកទៅតាមច្បាប់នោះឡើយ ។
- អ្នកជំនួយការងារផ្ទះអាចធ្វើការទាមទារ ឬទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្តពីនិយោជករបស់គាត់ / នាងសម្រាប់ការបញ្ឈប់គាត់ / នាងដោយមូលហេតុមិនសមហេតុផល លុះត្រាតែ ៖
  - គាត់ / នាងបានធ្វើការជាមួយនិយោជកតែម្នាក់ ដោយមិនតិចជាង២៤ខែ មុនពេលត្រូវបានបញ្ឈប់ និង
  - គាត់/នាងត្រូវបានបញ្ឈប់ពីការងារដោយមូលហេតុណាមួយក្រៅពីមូលហេតុដែលបានដូចបានបញ្ជាក់នៅក្នុងច្បាប់នេះ ។

**ស១០.២ តើមានមូលហេតុអ្វីខ្លះដែលមានការបញ្ឈប់អ្នកជំនួយការងារផ្ទះ?**

**ច** យោងតាមច្បាប់ការងារ មានមូលហេតុចំនួនប្រាំសំខាន់ៗដែលមានបង្កឱ្យការបញ្ឈប់អ្នកជំនួយការងារផ្ទះ ដូចជា ៖

- អាកប្បកិរិយា ការប្រព្រឹត្ត ឬទង្វើរបស់អ្នកជំនួយការងារផ្ទះ
- កម្រិតនៃសមត្ថភាព ឬគុណសម្បត្តិរបស់អ្នកជំនួយការងារផ្ទះក្នុងការបំពេញការងាររបស់គាត់
- ការបញ្ឈប់ការងារដោយសារនិយោជកលែងត្រូវការគាត់ឱ្យធ្វើបន្ត ឬលក្ខខណ្ឌផ្នែកប្រតិបត្តិចាំបាច់ និងស្រមស្របណាផ្សេងទៀតរបស់និយោជក
- លក្ខខណ្ឌតម្រូវទៅតាមច្បាប់ ឬ
- មូលហេតុសំខាន់ៗផ្សេងទៀត ។

**ស១០.៣ តើមានមូលហេតុ ឬលក្ខខណ្ឌអ្វីខ្លះដែលអ្នកជំនួយការងារផ្ទះអាចធ្វើការទាមទារ ឬទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្តពីនិយោជករបស់គាត់ / នាងសម្រាប់ការបញ្ឈប់គាត់ / នាងដោយមូលហេតុមិនសមហេតុផល និងការបញ្ឈប់មិនត្រឹមត្រូវទៅតាមច្បាប់?**

**ច** អ្នកជំនួយការងារផ្ទះអាចធ្វើការទាមទារ ឬទទួលបានសិទ្ធិសម្រាប់ការទទួលយកប្រាក់ថ្លៃសងជម្ងឺចិត្តពីនិយោជករបស់គាត់ / នាងសម្រាប់ការបញ្ឈប់គាត់ / នាងដោយមូលហេតុមិនសមហេតុផល និងការបញ្ឈប់មិនត្រឹមត្រូវទៅតាមច្បាប់បានលុះត្រាតែ ៖

- គាត់/នាងត្រូវបានបញ្ឈប់ពីការងារដោយមូលហេតុណាមួយក្រៅពីមូលហេតុដែលបានដូចបានបញ្ជាក់នៅក្នុងច្បាប់ និង
- ការបញ្ឈប់គាត់ដែលផ្ទុយខុសពីច្បាប់ (មើលខាងក្រោម) ។

**ស១០.៤ តើមានមូលហេតុ ឬលក្ខខណ្ឌអ្វីខ្លះដែលចាត់ជាការបញ្ឈប់ការងាររបស់អ្នកជំនួយការងារផ្ទះផ្ទុយខុសពីច្បាប់?**

**ច** ខាងក្រោមនេះ គឺជាការបញ្ឈប់ការងារផ្ទុយខុសពីច្បាប់ ៖

- ការបណ្តេញអ្នកជំនួយការងារផ្ទះជាស្ត្រីដែលត្រូវបានបញ្ជាក់ថាមានផ្ទៃពោះនិងបានផ្តល់ការជូនដំណឹងអំពីការមានផ្ទៃពោះ
- ការបញ្ឈប់ដោយសារអ្នកជំនួយការងារផ្ទះបានឈប់ដោយមានការសុំច្បាប់ឈឺដោយមានប្រាក់ឈ្នួល
- ការបញ្ឈប់ដោយសារអ្នកជំនួយការងារផ្ទះបានផ្តល់ភស្តុតាង ឬព័ត៌មាន
- ឬសួរអំពីការចូលជាធរមាននៃច្បាប់បទប្បញ្ញត្តិការងារ នៅពេលមានរឿងអ្វីកើតឡើងទៅលើគាត់ ឬទទួលរងរបួសដែលត្រូវបានចាត់ជាគ្រោះថ្នាក់ការងារ
- ការបញ្ឈប់ដោយសារអ្នកជំនួយការងារផ្ទះបានចូលរួមសកម្មភាព ឬចូលជាសមាជិកសហជីពណាមួយ
- ការបញ្ឈប់ដោយសារអ្នកជំនួយការងារផ្ទះទទួលរងរបួស
- មុនពេលនិយោជកចុះកិច្ចព្រមព្រៀងសម្រាប់សងជម្ងឺចិត្តអ្នកជួយធ្វើការ ឬមុនពេលផ្តល់នូវលិខិតបញ្ជាក់ការវាយតម្លៃលើអ្នកជំនួយការងារផ្ទះ ។

**ស១០.៥ តើថ្លៃសងជម្ងឺចិត្តសម្រាប់ការគាំពារការងារមានអ្វីខ្លះ?**

**ច** ថ្លៃសងជម្ងឺចិត្តសម្រាប់ការគាំពារការងារដែលត្រូវកំណត់ដោយសាលាជម្រះក្តីការងាររួមមានដីកាស្តីពីការចូលបម្រើការងារបន្តទៀត ការដាក់ឲ្យចូលបម្រើការងារសារជាថ្មី ថ្លៃសម្រាប់ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ឬសងជម្ងឺចិត្ត ។

(អ្នកអាចរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ"ដែលអាចរកបាននៅការិយាល័យផ្នែកទំនាក់ទំនងការងារសម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតស្តីពីលក្ខខណ្ឌនានាដែលនិយោជិតទទួលបានក្នុងការគាំពារពួកគេដោយយោងតាមផ្នែកការគាំពារការងារនៃច្បាប់បទប្បញ្ញត្តិការងារ និងប្រភេទនានានៃថ្លៃសងជម្ងឺចិត្តដែលនិយោជិតអាចធ្វើការទាមទារ ឬទទួលបាន និងនិតិវិធីក្នុងការទាមទារថ្លៃសងជម្ងឺចិត្ត) ។

# ១១ ការត្រឡប់មកមាតុភូមិវិញដោយឥតគិតថ្លៃ ប្រាក់ឧបត្ថម្ភ សម្រាប់ការហូបចុក និងការធ្វើដំណើរ

## សម្រាប់អ្នកជំនួយការងារផ្ទះ

**ស១១.១ តើនិយោជករបស់ខ្ញុំទទួលខុសត្រូវចំពោះការបង់ថ្លៃសំបុត្រធ្វើដំណើរត្រឡប់ទៅកន្លែងដើមកំណើតរបស់ខ្ញុំនៅពេលផុតកំណត់ ឬបញ្ចប់កិច្ចសន្យាឬទេ?**

**ច** ពិតប្រាកដណាស់ យោងទៅតាមកិច្ចសន្យាការងារធម្មតា
និយោជករបស់អ្នកនឹងផ្តល់ជូនអ្នកនូវសំបុត្រធ្វើដំណើរទៅមកដោយឥតគិតថ្លៃទៅកាន់កន្លែងដើមកំណើតរបស់អ្នកនៅពេលផុតកំណត់ឬបញ្ចប់កិច្ចសន្យា ។
ជាធម្មតានិយោជកផ្តល់ជូនអ្នកនូវសំបុត្រយន្តហោះសម្រាប់ធ្វើដំណើរវិលត្រឡប់ទៅកន្លែងដើមកំណើតរបស់អ្នក និងអាហារប្រចាំថ្ងៃ និងប្រាក់ឧបត្ថម្ភធ្វើដំណើរចំនួន ១០០
ដុល្លារហុងកុងក្នុងមួយថ្ងៃនៅពេលអ្នកត្រឡប់ទៅកន្លែងដើមកំណើតរបស់អ្នកវិញ ។

## សម្រាប់និយោជក

**ស១១.២ តើខ្ញុំគួរតែបង់ប្រាក់សម្រាប់ថ្លៃសំបុត្រធ្វើដំណើរទៅមករបស់អ្នកជំនួយកិច្ចការផ្ទះរបស់ខ្ញុំនៅពេលផុតកំណត់ ឬបញ្ចប់កិច្ចសន្យាដែរឬទេ? តើខ្ញុំគួរតែយកចិត្តទុកដាក់លើចំណុចអ្វីខ្លះផ្សេងទៀត?**

**ច** គួរតែ ។ នៅក្រោមកិច្ចសន្យាការងារធម្មតា
អ្នកគួរតែផ្តល់ជូនអ្នកជំនួយការងារផ្ទះរបស់អ្នកនូវសំបុត្រធ្វើដំណើរទៅមកដោយឥតគិតថ្លៃទៅកាន់កន្លែងដើមកំណើតរបស់គាត់នៅពេលផុតកំណត់ ឬបញ្ចប់កិច្ចសន្យា ។ អ្នកគួរតែផ្តល់សំបុត្រយន្តហោះ (រួមទាំងថ្លៃសេវាសម្រាប់ឥវ៉ាន់ផ្ញើក្នុងយន្តហោះ) ជូនអ្នកជំនួយការងារផ្ទះរបស់អ្នក
ពុំមែនផ្តល់សាច់ប្រាក់ដែលមានតម្លៃស្មើនឹងតម្លៃសំបុត្រយន្តហោះ
ដើម្បីកាត់បន្ថយឱកាសដែលអ្នកជំនួយការងារផ្ទះចេញដំណើរទៅកាន់កន្លែងជិតខាងផ្សេងទៀតដែលមិនមែនជាកន្លែងដើមកំណើតរបស់គាត់បន្ទាប់ពីទទួលបានប្រាក់ ។

ក្រៅពីនេះដើម្បីធ្វើអោយប្រាកដថាភាគីទាំងសងខាងមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការងារដែលពាក់ព័ន្ធនឹងការបំពេញកិច្ចសន្យាឬការបញ្ចប់កិច្ចសន្យាពួកយើងសូមផ្តល់យោបល់អោយលោកអ្នកពិភាក្សាពីការរៀបចំចេញដំណើរជាមួយនឹងអ្នកធ្វើការងារតាមផ្ទះរបស់អ្នក (ដូចជាថ្ងៃចេញដំណើរឬគោលដៅធ្វើដំណើរជាដើម)
មុនពេលធ្វើការទិញសំបុត្រយន្តហោះ ។

**ស១១.៣ តើខ្ញុំត្រូវចំណាយប្រាក់ប៉ុន្មានសម្រាប់អាហារ និងប្រាក់ឧបត្ថម្ភធ្វើដំណើររបស់អ្នកជំនួយការងារផ្ទះរបស់ខ្ញុំនៅក្រោមកិច្ចសន្យាការងារ?**

**ច** វាអាស្រ័យលើពេលវេលាដែលអ្នកជំនួយកិច្ចការផ្ទះរបស់អ្នកធ្វើដំណើរមកពីហុងកុងត្រឡប់ទៅកន្លែងដើមកំណើតវិញ ។
កិច្ចសន្យាការងារចែងថា អាហារប្រចាំថ្ងៃនិងប្រាក់ឧបត្ថម្ភធ្វើដំណើរគឺ ១០០ ដុល្លារហុងកុងក្នុងមួយថ្ងៃ ។
ប្រសិនបើអ្នកមិនផ្តល់សំបុត្រយន្តហោះដែលធ្វើដំណើរត្រង់ទៅកាន់កន្លែងដើមកំណើតរបស់អ្នកជំនួយការងារផ្ទះរបស់អ្នក អាចគិតថ្លៃអាហារប្រចាំថ្ងៃ និងប្រាក់ឧបត្ថម្ភបន្ថែមទៀតដោយសារតែចំនួនថ្ងៃធ្វើដំណើរបន្ថែម ។

# ១២ សំណួរ និងបណ្ដឹង

## សម្រាប់និយោជក និងអ្នកជំនួយការងារផ្ទះ

### សទ១២.១ តើយើងអាចពិគ្រោះសុំយោបល់ដំបូន្មាន ឬជំនួយដែលពាក់ព័ន្ធនឹងកិច្ចសន្យាការងារ ឬច្បាប់ការងារបាននៅកន្លែងណា?

**ច** អ្នកអាច ៖

- ហៅទូរសព្ទទៅកាន់នាយកដ្ឋានការងារសម្រាប់សេវាក្នុងការឆ្លើយតបនឹងសំនួរ តាមបណ្ដាញលេខ

  2717 1771 ពេញ២៤ម៉ោង (បណ្ដាញ២៤ម៉ោងនេះ គ្រប់គ្រងក្រោមខ្សែ"1823") :

  2157 9537 ( ខ្សែទូរសព្ទបន្ទាន់ដែលបានផ្ដល់សម្រាប់ស្ត្រីជំនួយការផ្ទះ)
- ទំនាក់ទំនងរកជំនួយដោយផ្ទាល់ពីការិយាល័យផ្នែកទំនាក់ទំនង នៃនាយកដ្ឋានការងារដែលនៅក្បែរកន្លែងធ្វើការរបស់អ្នក
- សូមរកមើលសៀវភៅ "ការណែនាំដ៏លម្អិតអំពីច្បាប់បទប្បញ្ញត្តិការងារ"ដែលបានសង្ខេបពីបទប្បញ្ញត្តិសំខាន់ៗនៃច្បាប់ ។ សៀវភៅណែនាំនេះ អាចរកបាននៅសាខាការិយាល័យផ្នែកទំនាក់ទំនងការងារនៃនាយកដ្ឋានការងារ ឬទាញយកឯកសារនេះតាមគេហទំព័ររបស់នាយកដ្ឋានការងារ(www.labour.gov.hk) ។ អាសយដ្ឋានរបស់សាខាការិយាល័យទាំងនេះមាននៅឧបសម្ព័ន្ធទី VI ។

### សទ១២.២ តើសេវាអ្វីខ្លះដែលត្រូវផ្ដល់ជូននាយកដ្ឋានការងារ ប្រសិនបើខ្ញុំមានវិវាទជាមួយអ្នកជំនួយការងារផ្ទះ / និយោជករបស់ខ្ញុំពាក់ព័ន្ធនឹងកិច្ចសន្យាការងារ ឬបទប្បញ្ញត្តិនានានៅក្នុងច្បាប់ការងារ?

**ច**

- ប្រសិនបើអ្នកមានបញ្ហា ឬចង់ធ្វើការទាមទារដែលមិនអាចដោះស្រាយដោយខ្លួនឯងបាន និងទាក់ទងទៅនឹងកិច្ចសន្យាការងារ ឬបទប្បញ្ញត្តិនានាយោងតាមច្បាប់ការងារ អ្នកអាចទំនាក់ទំនងរកជំនួយដោយផ្ទាល់ពីផ្នែកទំនាក់ទំនងការងារ ។
- ផ្នែកទំនាក់ទំនងការងារអាចផ្ដល់ជំនួយដល់និយោជក និងអ្នកជំនួយការងារផ្ទះក្នុងការដោះស្រាយវិវាទការងាររបស់ពួកគេ តាមរយៈការផ្ដល់សេវាសម្របសម្រួលផ្សះផ្សារដោយឥតគិតថ្លៃ ។ មន្ត្រីសម្របសម្រួលផ្សះផ្សារនឹងជួយសម្រួលដល់និយោជក និងអ្នកជំនួយការងារផ្ទះ ដើម្បីស្វែងរកដំណោះស្រាយមួយដែលភាគីទាំងពីរអាចទទួលយកបាន ។ ប្រសិនបើពុំមានដំណោះស្រាយណាមួយទេនោះ និងដោយមានការស្នើសុំពីភាគីពាក់ព័ន្ធ ពាក្យបណ្ដឹងទាមទារនឹងត្រូវបានបញ្ជូនទៅឱ្យគណៈវិនិច្ឆ័យពាក្យបណ្ដឹងទាមទារពាក់ព័ន្ធនឹងការងារកម្រិតស្រាល ឬសាលាជំនុំជម្រះសម្រាប់ការវិនិច្ឆ័យលើរឿងក្ដីទាក់ទងនឹងការងារ ដោយអាស្រ័យលើចំនួនទឹកប្រាក់ដែលភាគីពាក់ព័ន្ធបានធ្វើការទាមទារ ។

- ប្រសិនបើនិយោជកមិនអាចផ្តល់ប្រាក់ឈ្នួលដែលនៅជំពាក់ ឬប្រាក់សម្រាប់ការចំណាយផ្សេងទៀតដោយសារភាពក្ស័យធនរបស់និយោជក នោះអ្នកជំនួយការងារផ្ទះត្រូវរកជំនួយពីនាយកដ្ឋានផ្តល់ជំនួយផ្នែកច្បាប់ និងផ្នែកសន្តិសុខសុវត្ថិភាពប្រាក់ឈ្នួលដើម្បីដាក់ពាក្យស្នើសុំប្រាក់ជំនួយពីមូលនិធិការពារប្រាក់ឈ្នួលលើអសាធនភាព ។

**ស១២.៣ តើនិយោជកត្រូវបានកាត់ទោសពីបទមិនបានទូទាត់ប្រាក់រង្វាន់របស់តុលាការការងារ ឬគណៈកម្មការវិនិច្ឆ័យបណ្តឹងទាមទារសំណងការងារអប្បបរមាដែរឬទេ?**

**ច** និយោជកដែលមិនបានទូទាត់ប្រាក់រង្វាន់របស់តុលាការការងារ ឬគណៈកម្មការវិនិច្ឆ័យបណ្តឹងទាមទារសំណងការងារអប្បបរមាក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីថ្ងៃដែលត្រូវទូទាត់ ត្រូវបានកាត់ទោស និងកាត់ទោសដោយពិន័យជាប្រាក់ចំនួន $៣៥០,000 និងជាប់ពន្ធនាគាររយៈពេល ៣ ឆ្នាំ * ។

*សម្រាប់ព័ត៌មានលម្អិត សូមមើលច្បាប់បទប្បញ្ញត្តិការងារ និងខិត្តប័ណ្ណផ្សព្វផ្សាយដែលពាក់ព័ន្ធ ។

D. H. កិច្ចសន្យាលេខ. ___________

# កិច្ចសន្យាការងារ

(សម្រាប់អ្នកជួយធ្វើការផ្ទះដែលបានជ្រើសរើសពីបរទេស)

កិច្ចសន្យានេះត្រូវបានធ្វើឡើងរវាង________________________(“និយោជក”) និង____________________ (“អ្នកជួយធ្វើការ”) លើ ____________________________________ និងត្រូវអនុវត្តតាមលក្ខខណ្ឌដូចតទៅ ៖

១. ទីលំនៅដើមរបស់ អ្នកជួយធ្វើការ ក្នុងគោលបំណងនៃកិច្ចសន្យានេះគឺ________________________________ ___________________________________________________________________ ។

២. (ក)+ អ្នកជួយធ្វើការ ត្រូវបានជួលដោយ និយោជក ក្នុងនាមជាអ្នកជួយធ្វើការនៅតាមផ្ទះក្នុងកំឡុងពេលពីរឆ្នាំ ដែលចាប់ផ្តើមពីថ្ងៃដែល អ្នកជួយធ្វើការ មកដល់ទីក្រុងហុងកុង ។

(ខ)+ អ្នកជួយធ្វើការ ត្រូវបានជួលដោយ និយោជក ក្នុងនាមជាអ្នកជួយធ្វើការនៅតាមផ្ទះក្នុងកំឡុងពេលពីរឆ្នាំ ដែលចាប់ផ្តើមពីថ្ងៃ___________ ដែលជាកាលបរិច្ឆេទដែលអនុលោមតាមកាលបរិច្ឆេទនៃការផុតកំណត់នៃកិច្ចសន្យារបស់ D. H. លេខ______ សម្រាប់ការងារជាមួយ និយោជកដដែល ។

(គ)+ អ្នកជួយធ្វើការ ត្រូវបានជួលដោយនិយោជកក្នុងនាមជាអ្នកជួយធ្វើការនៅតាមផ្ទះក្នុងកំឡុងពេលពីរឆ្នាំ ដែលចាប់ផ្តើមពីថ្ងៃ ដែលប្រធានផ្នែកអន្តោប្រវេសន៍បានផ្តល់ការអនុញ្ញាតអោយអ្នកជួយធ្វើការក្នុងការស្នាក់នៅទីក្រុងហុងកុង ដើម្បីចាប់ផ្តើមការងារទៅតាមកិច្ចសន្យានេះ ។

៣. អ្នកជួយធ្វើការ ត្រូវធ្វើការ និងស្នាក់នៅឯទីលំនៅរបស់និយោជកដែលមានទីតាំងស្ថិតនៅ____________________ ___________________________________________________________________ ។

៤. (ក) អ្នកជួយធ្វើការ ត្រូវបំពេញតែភារកិច្ចទាក់ទងការងារផ្ទះ ដូចដែលបានចែងនៅក្នុងតារាងនៃទីកន្លែងស្នាក់នៅ និងភារកិច្ចទាក់ទងការងារផ្ទះអោយនិយោជកតែប៉ុណ្ណោះ ។

(ខ) អ្នកជួយធ្វើការ មិនត្រូវទទួលយក និងមិនត្រូវសម្រេចតាមនិយោជកដែលអោយទទួលយកការងារផ្សេងទៀតពីបុគ្គលដទៃផ្សេងទៀតទេ ។

(គ) និយោជក និង អ្នកជួយធ្វើការ បានទទួលស្គាល់ថា ប្បញ្ញត្តិ៤(ក) និង(ខ)នៃកិច្ចសន្យានេះ នឹងក្លាយជាផ្នែកមួយនៃលក្ខខណ្ឌក្នុងការស្នាក់នៅដែលត្រូវបានអនុវត្តលើអ្នកជួយធ្វើការ ដោយនាយកដ្ឋានអន្តោប្រវេសន៍ ដែលយោងលើការទទួលយល់ស្របពី អ្នកជួយធ្វើការ ដើម្បីធ្វើការនៅទីក្រុងហុងកុងតាមកិច្ចសន្យានេះ ។ ការបំពានលើចំនុចណាមួយ ឬចំណុចទាំងពីរនៃលក្ខខណ្ឌដែលបានលើកឡើងខាងលើនឹងធ្វើអោយ អ្នកជួយធ្វើការ និង/ឬ អ្នកជួយជ្រោមជ្រែង និងអ្នកសមគំនិតទទួលខុសត្រូវចំពោះបណ្តឹងព្រហ្មទណ្ឌ ។

*លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

+ អនុវត្តប្បញ្ញត្តិទាំង២A ២B ឬ២C ណាមួយដែលសមរម្យ

អត្តលេខ ៤០៧ (១១/២០១៦)

៥. (ក) និយោជក ត្រូវផ្តល់ប្រាក់ឈ្នួលដល់អ្នកជួយធ្វើការ ចំនួន__________________ដុល្លារហុងកុងក្នុងមួយខែ ។ ចំនួនប្រាក់ឈ្នួល មិនត្រូវតិចជាងប្រាក់ឈ្នួលអប្បបរមាដែលចេញដោយរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង ហើយនឹងត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យានេះ ។ និយោជកណាម្នាក់ដែលមិនបានផ្តល់ប្រាក់ឈ្នួល ដោយអនុវត្តតាមកិច្ចសន្យាការងារនេះ នឹងត្រូវទទួលខុសត្រូវចំពោះបណ្តឹងព្រហ្មទណ្ឌ ។

(ខ) និយោជក ត្រូវផ្តល់អោយ អ្នកជួយធ្វើការ នូវកន្លែងស្នាក់នៅសមរម្យ និងសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ដូចដែលបានចែងនៅក្នុងតារាងនៃកន្លែងស្នាក់នៅ និងភារកិច្ចការងារនៃផ្ទះ រួមជាមួយនឹងការផ្តល់ការហូបចុកដោយឥតគិតថ្លៃ ។ ប្រសិនបើគ្មានការផ្តល់ការហូបចុកទេ នោះត្រូវមានការផ្តល់ប្រាក់លើថ្លៃហូបចុកចំនួន_______________ដុល្លារហុងកុងក្នុងមួយខែ ទៅដល់អ្នកជួយធ្វើការ ។

(គ) និយោជក ត្រូវផ្តល់នូវវិក្កយបត្រក្នុងការបើកប្រាក់ឈ្នួល ព្រមទាំងថ្លៃហូបចុក ហើយអ្នកជួយធ្វើការ ត្រូវដឹងឮពីចំនួនប្រាក់ក្នុងវិក្កយបត្រ ដោយមានការចុះហត្ថលេខារបស់ គាត់/នាង* ។

៦. អ្នកជួយធ្វើការ មានសិទ្ធិឈប់រាល់ថ្ងៃសម្រាក ថ្ងៃសម្រាកកំណត់ដោយច្បាប់ និងការឈប់សម្រាកដោយមានប្រាក់ឈ្នួល ដូចដែលមានចែងនៅក្នុងបញ្ញត្តិការងារ ជំពូក៥៧ ។

៧. (ក) និយោជក ត្រូវផ្តល់អោយអ្នកជួយធ្វើការ នូវថ្លៃធ្វើដំណើរពីទីលំនៅដើមរបស់គាត់/នាង* ទៅកាន់ទីក្រុងហុងកុង និងនៅថ្ងៃបញ្ចប់ ឬថ្ងៃផុតកំណត់នៃកិច្ចសន្យានេះ ត្រូវចេញថ្លៃធ្វើដំណើរត្រលប់ទៅកាន់កន្លែងដើមឱ្យគាត់/នាង*វិញ ។

(ខ) ថ្លៃហូបចុកប្រចាំថ្ងៃ និងថ្លៃស្នាក់នៅចំនួន ១០០ដុល្លារហុងកុង ក្នុងមួយថ្ងៃ ត្រូវផ្តល់ជូនអ្នកជួយធ្វើការ ដោយគិតចាប់ពីថ្ងៃដែលគាត់/នាង* បានចាកចេញពីទីលំនៅដើម រហូតដល់ថ្ងៃដែល គាត់/នាង* បានមកដល់ទីក្រុងហុងកុង ប្រសិនបើជាការធ្វើដំណើរដែលទិសដៅត្រង់បំផុត ។ ការផ្តល់ជូននេះក៏ត្រូវធ្វើឡើង នៅពេលដែលអ្នកជួយធ្វើការត្រលប់ទៅទីលំនៅដើមរបស់គាត់/នាង*អាស្រ័យលើថ្ងៃផុតកំណត់ ឬការបញ្ចប់នៃកិច្ចសន្យានេះ ។

៨. និយោជក ត្រូវទទួលខុសត្រូវលើថ្លៃឈ្នួល និងការចំណាយដូចខាងក្រោម (ប្រសិនបើមាន) សម្រាប់ការចាកចេញពីទីលំនៅដើមរបស់គាត់/នាង* និងការចូលមកដល់ទីក្រុងហុងកុង ៖

i. ថ្លៃពិនិត្យសុខភាព
ii. ថ្លៃសេវាត្រួតពិនិត្យដោយស្ថានកុងស៊ុលដែលពាក់ព័ន្ធ
iii. ថ្លៃទិដ្ឋាការ
iv. ថ្លៃធានារ៉ាប់រង
v. ថ្លៃរដ្ឋបាល ឬថ្លៃរដ្ឋបាលការងារអន្តរជាតិហ្វីលីពីន ឬថ្លៃចំណាយផ្សេងៗទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលតម្រូវដោយអាជ្ញាធរ រដ្ឋាភិបាលដែលពាក់ព័ន្ធ និង
vi. ការចំណាយផ្សេងៗទៀត_______________________________________________

ក្នុងករណីដែល អ្នកជួយធ្វើការ បានផ្តល់ថ្លៃចំណាយ ឬថ្លៃឈ្នួលខាងលើ និយោជក ត្រូវបង្វិលសងទៅឱ្យអ្នកជួយធ្វើការវិញអោយគ្រប់ចំនួន ដែលអ្នកជួយធ្វើការបានចំណាយ ដោយយោងទៅតាមតម្រូវការ និងទំនិញដែលមានក្នុងវិកយបត្រ ឬឯកសារដែលជាភស្តុតាងនៃការចំណាយ ។

*លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

៩. (ក) ក្នុងករណីដែលអ្នកជួយធ្វើការ មានជំងឺ ឬទទួលរងរបួសដោយខ្លួនឯង ក្នុងអំឡុងពេលធ្វើការដូចមានចែងក្នុងប្បញ្ញត្តិទី២ និយោជកត្រូវផ្តល់នូវការព្យាបាលសុខភាពដោយឥតគិតថ្លៃទៅដល់អ្នកជួយធ្វើការ លើកលែងតែអំឡុងពេលដែលអ្នកជួយធ្វើការបានចាកចេញពីទីក្រុងហុងកុង ដោយឆន្ទៈរបស់គាត់/នាង* និងក្នុងគោលបំណងផ្ទាល់ខ្លួនរបស់គាត់/នាង*។ការចេញថ្លៃព្យាបាលសុខភាពនេះរួមបញ្ចូលទាំងការប្រឹក្សាសុខភាព ការថែទាំនៅមន្ទីរពេទ្យ និងការព្យាបាលជាបន្ទាន់ ។ អ្នកជួយធ្វើការ ត្រូវទទួលយកការព្យាបាលសុខភាព ដែលផ្តល់ដោយអ្នកអនុវត្តការព្យាបាលដែលបាន ចុះបញ្ជីរួច ។

(ខ) ប្រសិនបើអ្នកជួយធ្វើការ រងរបួសដោយគ្រោះថ្នាក់ ឬជំងឺវិជ្ជាជីវៈ កើតឡើងក្រៅម៉ោង ឬក្នុងម៉ោងធ្វើការ និយោជកត្រូវផ្តល់នូវសំណង ដែលយោងតាមជំពូកទី២៨២នៃប្បញ្ញត្តិនៃសំណងរបស់និយោជក ។

(គ) ក្នុងករណីដែលអ្នកព្យាបាល បញ្ជាក់ថា អ្នកជួយធ្វើការ មិនអាចធ្វើសេវាកម្មបន្តទៀត និយោជកត្រូវអនុវត្តទៅតាមប្បញ្ញត្តិដែលពាក់ព័ន្ធដើម្បីបញ្ចប់ការងារ និងត្រូវចាត់ចែងអោយអ្នកជួយធ្វើការ ធ្វើមាតុភូមិនិវត្តន៍ទៅទីលំនៅដើមរបស់គាត់/នាង*វិញ ដោយអនុលោមតាមប្បញ្ញត្តិទី៧ ។

១០. ភាគីទាំងពីរ ត្រូវបញ្ចប់កិច្ចសន្យានេះដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមុនមួយខែ ឬត្រូវបង់ជាប្រាក់ដែលស្មើនឹងប្រាក់ឈ្នួលមួយខែជំនួសអោយការជូនដំណឹង ។

១១. ផ្ទុយពីប្បញ្ញត្តិទី១០ ភាគីណាមួយដែលមានបំណងចង់បញ្ចប់កិច្ចសន្យានេះជាលាយលក្ខណ៍អក្សរ និងដោយមិនមានការជូនដំណឹងមុន ឬត្រូវពិន័យជាប្រាក់ជំនួសលើការមិនបានជូនដំណឹង ដោយយោងទៅតាមជំពូកទី៥៧នៃប្បញ្ញត្តិក្នុងច្បាប់ការងារ ។

១២. ក្នុងករណីបញ្ចប់កិច្ចសន្យា ទាំងភាគីនិយោជក និងអ្នកជួយធ្វើការ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ប្រធានផ្នែកអន្តោរប្រវេសន៍ក្នុងកំឡុងពេលប្រាំពីរថ្ងៃនៃថ្ងៃដែលបញ្ចប់កិច្ចសន្យា ។ សេចក្តីចម្លងជាលាយលក្ខណ៍អក្សរដែលទទួលស្គាល់ការបញ្ចប់កិច្ចសន្យារបស់ភាគីណាម្នាក់ ក៏ត្រូវផ្ញើរជូនប្រធានអន្តោប្រវេសន៍ផងដែរ ។

១៣. ភាគីទាំងពីរអាចអនុវត្តកិច្ចសន្យាថ្មីដោយយោងតាមថ្ងៃផុតកំណត់នៃកិច្ចសន្យាដែលមានស្រាប់ អ្នកជួយធ្វើការត្រូវត្រលប់ទៅកន្លែងដើមរបស់គាត់/នាង* ដែលបន្ទុកចំណាយគឺចេញនិយោជក សម្រាប់វិសម្សកាលដែលមាន/គ្មានប្រាក់ឈ្នួល* មិនតិចជាងប្រាំពីរថ្ងៃ លើកលែងមានការយល់ព្រមជាមុនក្នុងការពន្យាពេលស្នាក់នៅទីក្រុងហុងកុងដែលត្រូវបានផ្តល់ដោយប្រធានផ្នែកអន្តោប្រវេសន៍ នៅមុនពេលដែលមានការចាប់ផ្តើមផ្សេងទៀត ។

១៤. ក្នុងករណីអ្នកជួយធ្វើការ ទទួលមរណៈភាព និយោជកត្រូវចេញថ្លៃបញ្ជូនសាកសព និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកជួយធ្វើការ ពីទីក្រុងហុងកុងទៅទីលំនៅដើមរបស់គាត់/នាង*វិញ ។

*លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

១៥. បម្រែបម្រួលដែលបានចែងដូចមាននៅខាងក្រោម ការបម្រែបម្រួលណាមួយ ឬការបន្ថែមលើលក្ខខណ្ឌក្នុងកិច្ចសន្យានេះ (រួមបញ្ចូលទាំងឧបសម្ព័ន្ធតារាងនៃកន្លែងស្នាក់នៅនិងភារកិច្ចនៃការងារតាមផ្ទះ)ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា នឹងត្រូវបានចាត់ទុកជាមោឃៈលើកលែងបានធ្វើឡើងដោយការព្រមព្រៀងជាមុនពីស្ថានការទទួលបន្ទុកការងារ ៖

(ក) បម្រែបម្រួលនៃម៉ោងធ្វើការ ដែលមានចែងក្នុងបញ្ញត្តិទី២
អាស្រ័យលើការពន្យាពេលដូចដែលបានដែលបានលើកឡើងខាងលើ ដោយមិនលើសពីមួយខែ
និងមានការព្រមព្រៀងគ្នាទៅវិញទៅមក និងមានការយល់ព្រមជាមុនពីប្រធានផ្នែកអន្តោប្រវេសន៍ ។

(ខ) បម្រែបម្រួលនៃអាសយដ្ឋានទីកន្លែងស្នាក់នៅរបស់និយោជក ដែលបានចែងក្នុងប្បញ្ញត្តិទី៣
អាស្រ័យលើការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានផ្តល់ជូនប្រធានផ្នែកអន្តោប្រវេសន៍ដែលបានចែងថា
អ្នកជួយធ្វើការ ត្រូវបន្តធ្វើការ និងស្នាក់នៅក្នុងទីលំនៅថ្មីរបស់និយោជក ។

(គ) បម្រែបម្រួលក្នុងតារាងនៃការស្នាក់នៅ
និងភារកិច្ចនៃការងារតាមផ្ទះធ្វើក្នុងលក្ខខណ្ឌដូចដែលបានចែងក្នុងចំណុចទី៧នៃតារាងនៃការស្នាក់នៅ
និងភារកិច្ចក្នុងការងារតាមផ្ទះ និង

(ឃ) បម្រែបម្រួលនៃចំនុចទី៤ នៃតារាងនៃការស្នាក់នៅ និងភារកិច្ចនៃការងារតាមផ្ទះ
គឺត្រូវអនុលោមទៅតាម ការជិះទោចក្រយានយន្ត យានយន្ត ដោយអ្នកជួយធ្វើការ
តាមកិច្ចព្រមព្រៀងគ្នាទៅវិញទៅមកនៃសេចក្តីបន្ថែមទៅលើតារាង
និងការអនុញ្ញាតជាលាយលក្ខណ៍អក្សរដែលផ្តល់ជូនដោយ ប្រធានផ្នែកអន្តោរប្រវេសន៍ដល់អ្នកជួយធ្វើការ
ដើម្បីបំពេញភារកិច្ចក្នុងការបើកបរ មិនថាវាជាកម្មសិទ្ធិរបស់និយោជក ឬមិនមែនក៏ដោយ ។

១៦. លក្ខខណ្ឌខាងលើមិនមែនទប់ស្កាត់ អ្នកជួយធ្វើការ ពីការទទួលបានសិទ្ធិ ទៅតាមជំពូកទី៥៧នៃប្បញ្ញត្តិស្តីពីការងារ ជំពូកទី២៨២នៃប្បញ្ញត្តិពីការសងសំណងរបស់និយោជក និងប្បញ្ញត្តិដែលពាក់ព័ន្ធដទៃទៀត ។

១៧. ភាគីនៃកិច្ចសន្យានេះ ព្រមព្រៀងគ្នាថា អ្នកជួយធ្វើការ បានត្រួតពិនិត្យសុខភាពត្រឹមត្រូវ និងសមស្របតាមការងាររបស់គាត់/នាង សម្រាប់ការងារក្នុងនាមជាអ្នកជួយធ្វើការនៅតាមផ្ទះ ហើយវិញ្ញាបនបត្រវេជ្ជសាស្ត្រត្រូវបានផ្តល់ឱ្យនិយោជក សម្រាប់ការចុះអធិការកិច្ច ។

បានចុះហត្ថលេខាដោយ និយោជក________________________________

(ហត្ថលេខារបស់និយោជក)

មានវត្តមានដោយ_________________________ ______________________________________

(ឈ្មោះរបស់សាក្សី) (ហត្ថលេខារបស់សាក្សី)

បានចុះហត្ថលេខាដោយ អ្នកជួយធ្វើការ____________________________

(ហត្ថលេខារបស់អ្នកជួយធ្វើការ)

មានវត្តមានដោយ_________________________ ______________________________________

(ឈ្មោះរបស់សាក្សី) (ហត្ថលេខារបស់សាក្សី)

*លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

ទុកជាឯកសារយោងប៉ុណ្ណោះ

# តារាងនៃការស្នាក់នៅ និងភារកិច្ចនៃការងារតាមផ្ទះ

១. ទាំងនិយោជក និងអ្នកជួយធ្វើការ ត្រូវចុះហត្ថលេខាដើម្បីទទួលស្គាល់ថា ភាគីទាំងពីរបានអាន និងយល់ព្រមលើខ្លឹមសារនៃតារាងនេះ និងបញ្ជាក់ពីការព្រមព្រៀងរបស់ភាគីទាំងពីរទៅដល់នាយកដ្ឋានអន្តោប្រវេសន៍ និងអាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រមូល និងប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងតារាងនេះដោយអនុលោមតាមបញ្ញត្តិនៃទិន្នន័យផ្ទាល់ខ្លួន(សិទ្ធិឯកជន) ។

២. ទីលំនៅរបស់និយោជក និងចំនួនបុគ្គលដែលត្រូវបម្រើការងារ

ក. ទំហំប្រហាក់ប្រហែលរបស់ផ្ទះល្វែង/ផ្ទះ____________ហ្វីតការ៉េ/ម៉ែត្រការ៉េ*

ខ. បានចែងនៅខាងក្រោមអំពីចំនួនមនុស្សដែលត្រូវបានធ្វើការនៅមូលដ្ឋានធម្មតា ៖

មនុស្សពេញវ័យ________នាក់ អនីតិជន(អាយុចន្លោះពី៥ទៅ១៨ឆ្នាំ)________នាក់ អនីតិជន (អាយុក្រោម៥ឆ្នាំ)__________នាក់ លើកលែងតែទារកក្នុងផ្ទៃ ។ សមាជិកក្នុងគ្រួសារ_________នាក់ ដែលត្រូវការ ការថែទាំជាប់លាប់ ឬការយកចិត្តទុកដាក់(លើកលែងទារក) ។

(សម្គាល់ ៖ ចំនួននៃអ្នកជួយធ្វើការ ដែលបានបម្រើការងារបច្ចុប្បន្នឱ្យ និយោជក ដើម្បីបម្រើសមាជិកក្នុងគ្រួសារ_______នាក់) ។

៣. កន្លែងស្នាក់នៅ និងកិច្ចការដែលត្រូវផ្តល់អោយអ្នកជួយធ្វើការ

ក. កន្លែងស្នាក់នៅសម្រាប់អ្នកជួយធ្វើការ

ដោយសារតែទំហំផ្ទះល្វែងជាមធ្យមនៅក្នុងទីក្រុងហុងកុងគឺមានទំហំរាងតូច ហើយលទ្ធភាពដែលអាចចែកបន្ទប់អ្នកបម្រើគឺមិនមែនជារឿងធម្មតាទេ និយោជក ត្រូវផ្តល់អោយ អ្នកជួយធ្វើការនូវកន្លែងស្នាក់នៅដែលសមរម្យ ជាមួយនឹងសិទ្ធិឯកជនរបស់គាត់ឱ្យសមហេតុផល ។ ឧទាហរណ៍នៃកន្លែងស្នាក់នៅដែលមិនសមរម្យគឺ ៖ អ្នកជួយធ្វើការគេងនៅលើគ្រែដែលមានច្រើនជាន់នៅច្រករបៀងផ្ទះ ជាមួយនឹងការប្រើប្រាស់សិទ្ធិឯកជនមិនសូវបានទូលំទូលាយ និងការគេងរួមបន្ទប់ជាមួយនឹងមនុស្សពេញវ័យ/ក្មេងជំទង់ដែលមានភេទផ្ទុយគ្នា ។

☐ ចាស/បាទ ទំហំដែលបានប៉ាន់ប្រមាណនូវបន្ទប់របស់អ្នកបម្រើ__________ហ្វីតការ៉េ/ម៉ែត្រការ៉េ*

☐ ទេ ការរៀបចំការគេងសម្រាប់អ្នកជួយធ្វើការ ៖

☐ រួមបន្ទប់ជាមួយនឹងក្មេង/ក្មេងៗ_______នាក់ អាយុ___________

☐ កន្លែងខណ្ឌដោយឡប់ឡែ___________ការ៉េហ្វីត/ម៉ែត្រការ៉េ*

☐ ក្រៅពីនេះ សូមបកស្រាយ_____________________________________________ ______________________________________________________________ ។

ទុកជាឯកសារយោងប៉ុណ្ណោះ

* លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

☐ គូសនៅក្នុងប្រអប់ដែលសមរម្យ

៣. សម្ភារៈដែលត្រូវបានផ្តល់ជូនទៅអ្នកជួយធ្វើការ ៖

(សម្គាល់ ៖ ពាក្យសម្រាប់ទិដ្ឋាការចូលជាធម្មតានឹងមិនយល់ព្រម ប្រសិនបើសម្ភារៈសំខាន់ៗក្នុងចំនុចពី (ក) ដល់(ច) មិនបានផ្តល់ដោយឥតគិតថ្លៃ ។

| | | |
|---|---|---|
| (ក). ការផ្គត់ផ្គង់ភ្លើង និងទឹក | ☐ ចាស/បាទ | ☐ ទេ |
| (ខ). សម្ភារៈបង្គន់ និងបន្ទប់ទឹក | ☐ ចាស/បាទ | ☐ ទេ |
| (គ). គ្រែ | ☐ ចាស/បាទ | ☐ ទេ |
| (ឃ). ភួយ ឬ ផាហ៊ុំ | ☐ ចាស/បាទ | ☐ ទេ |
| (ង). ខ្នើយ | ☐ ចាស/បាទ | ☐ ទេ |
| (ច). ទូខោអាវ | ☐ ចាស/បាទ | ☐ ទេ |
| (ឆ). ទូទឹកកក | ☐ ចាស/បាទ | ☐ ទេ |
| (ជ). តុ | ☐ ចាស/បាទ | ☐ ទេ |

(ឈ). សម្ភារៈផ្សេងៗទៀត (សូមបរិយាយ) ______________________

______________________

______________________

៤. អ្នកជួយធ្វើការ ត្រូវអនុវត្តតែការងារក្នុងផ្ទះ នៅទីលំនៅរបស់និយោជកតែប៉ុណ្ណោះ ។ ភារកិច្ចនៃការងារតាមផ្ទះត្រូវអនុវត្តដោយអ្នកជួយធ្វើការក្រោមកិច្ចសន្យានេះ ដោយមិនរាប់បញ្ចូលការបើកបរទោចក្រយានយន្ត យានយន្ត ដែលបានចែងក្នុងគោលបំណងណាក៏ដោយ ទោះវាជាកម្មសិទ្ធិរបស់និយោជក ឬមិនមែនក៏ដោយ ។

៥. ភារកិច្ចនៃការងារតាមផ្ទះមានដូចខាងក្រោមនេះ
ផ្នែកសំខាន់នៃភារកិច្ចនៃការងារតាមផ្ទះ ៖

ក. ការងារមើលខុសត្រូវសមាជិកក្នុងផ្ទះ
ខ. ចំអិនម្ហូបអាហារ
គ. មើលថែមនុស្សចាស់ជរានៅក្នុងគ្រួសារ(មើលថែជាប់លាប់ ឬយកចិត្តទុកដាក់គឺត្រូវបានតម្រូវ/មិនតម្រូវ*)
ឃ. មើលថែទារក
ង. មើលថែក្មេងៗ
ច. ផ្សេងៗទៀត(សូមបញ្ជាក់) ______________________

______________________

៦. នៅពេលដែលតម្រូវអោយអ្នកជួយធ្វើការ សម្អាតបង្អួចខាងក្រៅដែលមិនស្ថិតនៅជាន់ផ្ទាល់ដី ឬនៅជិតយ៉មុខផ្ទះ (ដែលវាត្រូវតែមានសុវត្ថិភាពដោយសមហេតុសមផលសម្រាប់អ្នកជួយធ្វើការក្នុងការធ្វើការ) ឬច្រករបៀងផ្ទះធម្មតា (“លាងសម្អាតផ្នែកខាងក្រៅនៃបង្អួច”)ការសម្អាតផ្នែកខាងក្រៅនៃបង្អួចត្រូវតែស្ថិតនៅក្រោមលក្ខខណ្ឌដូចតទៅនេះ ៖

* លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

☐ គូសនៅក្នុងប្រអប់ដែលសមរម្យ

(i) បង្អួចដែលនឹងត្រូវសម្អាត ត្រូវបំពាក់ដោយសំណាញ់ដែលបិទបើកបាន ឬមានសុវត្ថិភាពក្នុងសភាពដែលអាចការពារសំណាញ់ពីការរបើក និង

(ii) មិនត្រូវឱ្យផ្នែកណាមួយនៃរាងកាយរបស់អ្នកជួយធ្វើការឈោងហួសពីប្រវែងបង្អួចលើកលែងតែដៃ ។

៧. និយោជកត្រូវផ្តល់ព័ត៌មានដល់អ្នកជួយធ្វើការ និងប្រធានអន្តោប្រវេសន៍ក្នុងការផ្លាស់ប្តូរណាមួយនៃចំនុចទី២ ៣ និង៥ ដោយរក្សាទុកច្បាប់ចម្លងនៃតារាងការស្នាក់នៅ
និងភារកិច្ចនៃការងារតាមផ្ទះដែលបានកែសម្រួលហើយ(ID 407G) ដែលបានចុះហត្ថលេខាដោយនិយោជក និងអ្នកជួយធ្វើការដើម្បីអោយប្រធានផ្នែកអន្តោប្រវេសន៍រក្សាទុកជាកំណត់ហេតុ ។

ទុកជាឯកសារយោងតែប៉ុណ្ណោះ

| ឈ្មោះនិងហត្ថលេខារបស់និយោជក | កាលបរិច្ឆេទ | ឈ្មោះនិងហត្ថលេខារបស់អ្នកជួយធ្វើការ | កាលបរិច្ឆេទ |
|---|---|---|---|

* លុបបាននៅត្រង់ចំណុចដែលមិនសមរម្យ

☐ គូសនៅក្នុងប្រអប់ដែលសមរម្យ

**ឧបសម្ព័ន្ធទី II**

# គំរូនៃវិក័យបត្រសម្រាប់សំណងលើថ្លៃរត់ ឬរៀបចំឯកសារ

ខ្ញុំឈ្មោះ ________________________________ កាន់អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែនលេខ ________________ សូមទទួលស្គាល់ចំពោះការទទួលបានការបង្វិលសងលើថ្លៃរត់ ឬរៀបចំឯកសារ ពីនិយោជករបស់ខ្ញុំឈ្មោះ______________________________ នៅ (កាលបរិច្ឆេទ) ___________________

* បើកជាប្រាក់សុទ្ធ / តាមរយៈមូលប្បទានបត្រ (សែក) / តាមរយៈការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិតាមធនាគារ ។

| | | |
|---|---|---|
| (ក) | ថ្លៃធានារ៉ាប់រងតាមផ្លូវច្បាប់ | $ ________________ |
| (ខ) | ថ្លៃពិនិត្យសុខភាព | $ ________________ |
| (គ) | ថ្លៃលើលិខិតបញ្ជាក់ | $ ________________ |
| (ឃ) | ថ្លៃទិដ្ឋាការ | $ ________________ |
| (ង) | ថ្លៃរដ្ឋបាលហ្វីលីពីនសម្រាប់ការងារក្រៅប្រទេស (POEA) | $ ________________ |
| (ច) | ផ្សេងៗ | $ ________________ |

បានទទួលដោយ (ហត្ថលេខា)៖ ________________________________

(ឈ្មោះ)៖ (                                        )

សាក្សី (ប្រសិនបើមាន)(ហត្ថលេខា)៖ ________________________________

(ឈ្មោះ)៖ (                                        )

សម្គាល់ទី ១៖ សូមរកមើល “សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង”សម្រាប់ព័ត៌មានទាក់ទងសិទ្ធិ និងកាតព្វកិច្ចរបស់និយោជក និងអ្នកជំនួយការងារផ្ទះមកពីបរទេស ។

សម្គាល់ទី ២៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឭកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

* សូមលុបចោលចំណុចដែលមិនសមស្រប

ឧបសម្ព័ន្ធទី III ក

# គំរូនៃវិក័យបត្រប្រាក់ឈ្នួលផ្តល់ឱ្យអ្នកជំនួយការងារផ្ទះដែលបានមកពីបរទេស

ខ្ញុំឈ្មោះ____________________________________កាន់អត្តសញ្ញាណប័ណ្ណហុងកុងលេខ /លិខិតឆ្លងដែនលេខ

__________________ សូមទទួលស្គាល់ចំពោះការទទួលបានប្រាក់សម្រាប់ចំណុចមួយចំនួនដូចខាងក្រោម

ពីនិយោជករបស់ខ្ញុំឈ្មោះ ____________________________ នៅ (កាលបរិច្ឆេទ) ______________________

*បើកជាប្រាក់សុទ្ធ / តាមរយៈមូលប្បទានបត្រ (សែក) / តាមរយៈការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិតាមធនាគារ ។

១. ប្រាក់ឈ្នួល (ចាប់ពី ______________រហូតដល់ ______________) $______________

២. ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុក (ចាប់ពី ______________រហូតដល់ ______________) $______________

(ប្រសិនបើពុំមានការផ្តល់ជូននូវម្ហូបអាហារស្រាប់នោះទេ)

បានទទួលដោយ (ហត្ថលេខា)៖ ______________________________________________________

(ឈ្មោះ)៖ ( )

សាក្សី (ប្រសិនបើមាន)(ហត្ថលេខា)៖ ______________________________________________________

(ឈ្មោះ)៖ ( )

សម្គាល់ទី ១៖ ប្រាក់ឈ្នួលរបស់អ្នកជំនួយការងារផ្ទះមកពីបរទេស (FDH) មិនត្រូវតិចជាងប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ (MAW) នៅពេលដែលមានការចុះហត្ថលេខាកិច្ចសន្យាការងារស្តង់ដារ (SEC) ។

សម្គាល់ទី ២៖ សូមរកមើល "សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង" សម្រាប់ព័ត៌មានទាក់ទងសិទ្ធិ និងកាតព្វកិច្ចរបស់និយោជក និងអ្នកជំនួយការងារផ្ទះមកពីបរទេស ។

សម្គាល់ទី ៣៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឭកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

* សូមលុបចោលចំណុចដែលមិនសមស្រប

# កំណត់ត្រាច្បាប់ឈប់សម្រាករបស់អ្នកជំនួយការងារផ្ទះមកពីបរទេស

ខែ__________ឆ្នាំ ______

ឈ្មោះរបស់អ្នកជំនួយការងារផ្ទះមកពីបរទេស ៖ ______________________

(I) ថ្ងៃឈប់សម្រាក (សម្គាល់ទី ១)

| ថ្ងៃឈប់សម្រាកដែលបានប្រើនៅថ្ងៃ (កាលបរិច្ឆេទ) | ហត្ថលេខា របស់អ្នកជំនួយការងារផ្ទះ មកពីបរទេស |
|---|---|
| | |
| | |
| | |
| | |

(II) ថ្ងៃឈប់សម្រាកបុណ្យជាតិ (សម្គាល់ទី ២)

| ថ្ងៃឈប់សម្រាកបុណ្យជាតិដែលបានប្រើនៅថ្ងៃ (កាលបរិច្ឆេទ) | ឈ្មោះនៃថ្ងៃឈប់សម្រាកបុណ្យជាតិ (សូមបញ្ជាក់) | ហត្ថលេខា របស់អ្នកជំនួយការងារផ្ទះ មកពីបរទេស |
|---|---|---|
| | | |
| | | |
| | | |

(III) ច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល (សម្គាល់ទី ៣)

| រយៈពេលនៃការសុំច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល (កាលបរិច្ឆេទ) | | ហត្ថលេខា របស់អ្នកជំនួយការងារផ្ទះ មកពីបរទេស |
|---|---|---|
| ចាប់ពីថ្ងៃ | រហូតដល់ថ្ងៃ | |
| | | |
| | | |
| | | |
| | | |

(IV) ផ្សេងៗ (ឧទាហរណ៍ ច្បាប់ឈឺដោយមានប្រាក់ឈ្នួលជាដើម)

| ច្បាប់ឈប់សម្រាកដែលបានប្រើនៅថ្ងៃ (កាលបរិច្ឆេទ) | មូលហេតុការដាក់ច្បាប់ (សូមបញ្ជាក់) | ហត្ថលេខា របស់អ្នកជំនួយការងារផ្ទះ មកពីបរទេស |
|---|---|---|
| | | |
| | | |
| | | |

សម្គាល់ទី ១៖ អ្នកជំនួយការងារផ្ទះមកពីបរទេស មានសិទ្ធិទទួលបានថ្ងៃឈប់សម្រាកយ៉ាងតិច១ថ្ងៃនៅរៀងរាល់១សប្តាហ៍ ។ សូមរកមើល "សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង"សម្រាប់ព័ត៌មានលម្អិត ។

សម្គាល់ទី ២៖ មួយ "FDH"(" អ្នក ជួយ ក្នុង ស្រុក បរទេស"), ដោយមិនគិតពីគាត់/ប្រវែង នៃ ការ បម្រើ របស់ នាង, មាន សិទ្ធិ ទទួល បាន ថ្ងៃ ឈប់ សម្រាក តាម ច្បាប់ ។

សូមរកមើល "សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង"សម្រាប់ព័ត៌មានលម្អិត ។

សម្គាល់ទី ៣៖ អ្នកជំនួយការងារផ្ទះមកពីបរទេស មានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ បន្ទាប់ពីបានធ្វើការជាមួយនិយោជកតែម្នាក់ ចំនួន១២ខែ ។ អ្នកជំនួយការងារផ្ទះមកពីបរទេសនឹងទទួលបាន ចំនួនថ្ងៃនៃច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ដែលកើនឡើងពី៧ថ្ងៃរហូតដល់១៤ថ្ងៃ យោងតាមរយៈពេលនៃការបម្រើការងាររបស់គាត់ ។ សូមរកមើល "សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង"សម្រាប់ព័ត៌មានលម្អិត ។

សម្គាល់ទី ៤៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឮកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

# គំរូលិខិតបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ដោយអ្នកជំនួយការងារផ្ទះមកពីបរទេស

_______(ឈ្មោះរបស់និយោជក)_______ជាទីគោរព

ខ្ញុំឈ្មោះ___________________________ មានបំណងសុំបញ្ចប់កិច្ចសន្យាការងាររបស់ខ្ញុំជាមួយអ្នកក្នុងនាមជាអ្នកជំនួយការងារផ្ទះ យោងតាមកិច្ចសន្យាអ្នកជួយធ្វើការផ្ទះ លេខ ________________ ។

(សូម "✓" តាមការគួរ)

☐ ដោយជូនដំណឹងដល់អ្នកចំនួន ________________ ថ្ងៃ/ខែ * ។

☐ ដោយផ្តល់ប្រាក់ជូនអ្នកចំនួន ________________ ថ្ងៃ/ខែ * ជំនួសឲ្យការជូនដំណឹង ។

☐ ដោយគ្មានការជូនដំណឹង ។

☐ ដោយគ្មានការផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹងឡើយ ។

ថ្ងៃធ្វើការចុងក្រោយគឺ ________(កាលបរិច្ឆេទ)________.

មូលហេតុនៃការបញ្ចប់កិច្ចសន្យា (ប្រសិនបើមាន)៖

______________________________________________

______________________________________________

______________________________________________

សូមទទួលការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

________________ (ហត្ថលេខារបស់និយោជិត)

( ) (ឈ្មោះរបស់និយោជិត)

________________ (កាលបរិច្ឆេទ)

បានទទួលស្គាល់នូវវិក័យបត្រដែលបានទទួលពីនិយោជក ________________ (ហត្ថលេខា)

( ) (ឈ្មោះ)

________________ (កាលបរិច្ឆេទ)

សម្គាល់ទី ១៖ សូមរកមើល"សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង"សម្រាប់ព័ត៌មានទាក់ទងសិទ្ធិ និងកាតព្វកិច្ចរបស់និយោជកនិងអ្នកជំនួយការងារផ្ទះមកពីបរទេសដែលពាក់ព័ន្ធនឹងការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ។

សម្គាល់ទី ២៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឭកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

* សូមលុបចោលចំណុចដែលមិនសមស្រប

# គំរូលិខិតបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ដោយនិយោជករបស់អ្នកជំនួយការងារផ្ទះ ដែលបានមកពីបរទេស

__________(ឈ្មោះរបស់អ្នកជំនួយការងារផ្ទះ)__________ជាទីរាប់អាន

ខ្ញុំឈ្មោះ______________________________

មានបំណងចង់បញ្ចប់កិច្ចសន្យាការងាររបស់អ្នកដែលជាអ្នកជំនួយការងារផ្ទះ យោងតាមកិច្ចសន្យាអ្នកជំនួយការងារផ្ទះ លេខ ____________________ ។

(សូម “✓” តាមការគួរ)

☐ ដោយជូនដំណឹងដល់អ្នកចំនួន ____________________ ថ្ងៃ/ខែ * ។

☐ ដោយផ្តល់ប្រាក់ជូនអ្នកចំនួន ____________________ ថ្ងៃ/ខែ * ជំនួសឲ្យការជូនដំណឹង ។

☐ ដោយគ្មានការជូនដំណឹង ។

☐ ដោយគ្មានការផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹងឡើយ ។

ថ្ងៃធ្វើការចុងក្រោយរបស់អ្នកគឺ ________(កាលបរិច្ឆេទ)________ ។

មូលហេតុនៃការបញ្ចប់កិច្ចសន្យា (ប្រសិនបើមាន)៖

____________________________________________________________

____________________________________________________________

____________________________________________________________

សូមទទួលការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

____________________ (ហត្ថលេខារបស់និយោជក)

(                    ) (ឈ្មោះរបស់និយោជក)

____________________ (កាលបរិច្ឆេទ)

បានទទួលស្គាល់នូវវិក័យបត្រដែលបានទទួលពីនិយោជិត ____________________ (ហត្ថលេខា)

(                    ) (ឈ្មោះ)

____________________ (កាលបរិច្ឆេទ)

សម្គាល់ទី ១៖ សូមរកមើលជំពូកទី៨នៃ“សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេស និងនិយោជករបស់ពួកគេគួរយល់ដឹង”សម្រាប់ព័ត៌មានទាក់ទងសិទ្ធិ និងកាតព្វកិច្ចរបស់និយោជក និងអ្នកជំនួយការងារផ្ទះមកពីបរទេសដែលពាក់ព័ន្ធនឹងការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ ។

សម្គាល់ទី ២៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឭកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

* សូមលុបចោលចំណុចដែលមិនសមស្រប

# គំរូនៃវិក័យបត្រសម្រាប់ការចំណាយនៅពេលបញ្ចប់កិច្ចសន្យាការងារ មុនពេលកំណត់ / តាមកាលកំណត់

ខ្ញុំឈ្មោះ________________________________ កាន់អត្តសញ្ញាណប័ណ្ណហុងកុងលេខ/លិខិតឆ្លងដែនលេខ ________________ ទទួលបានប្រាក់តាមចំណុចខាងក្រោម ពីនិយោជករបស់ខ្ញុំឈ្មោះ ________________________ នៅ (កាលបរិច្ឆេទ) ___________________ *ជាប្រាក់សុទ្ធ / តាមរយៈមូលប្បទានបត្រ (សែក) / តាមរយៈការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិតាមធនាគារ ។

១ ប្រាក់ឈ្នួល (ចាប់ពីថ្ងៃ __________ រហូតដល់ថ្ងៃ ______________________) $____________
រួមបញ្ចូលទាំងការផ្តល់ប្រាក់តាមចំណុចខាងក្រោម ៖
(ក) ថ្ងៃឈប់សម្រាកបុណ្យជាតិ (កាលបរិច្ឆេទ ៖ __________________________) $____________
(ខ) ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ (ចាប់ពីថ្ងៃ __________ រហូតដល់ថ្ងៃ ___________) $____________
(គ) ច្បាប់ឈឺ (ចាប់ពីថ្ងៃ ________ រហូតដល់ថ្ងៃ ___________) $____________
(ឃ) ផ្សេងៗ (សូមបញ្ជាក់) ៖ __________________________ $____________
២ ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុក (ចាប់ពីថ្ងៃ _________ រហូតដល់ថ្ងៃ ___________) $____________
៣ ការផ្តល់ប្រាក់ជំនួសឲ្យការជូនដំណឹង $____________
៤ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំដែលមិនបានប្រើ (ចំនួនថ្ងៃ__________________________) $____________
៥ ប្រាក់ដែលផ្តល់ឱ្យក្រោយឈប់ធ្វើការ / ប្រាក់សម្រាប់បញ្ឈប់អ្នកជំនួយការងារផ្ទះ ដោយជំនួសការមិនបានបន្តកិច្ចសន្យា $____________
៦ ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុក និងការធ្វើដំណើរ $____________
៧ សំបុត្រយន្តហោះទៅមកកន្លែងដើមកំណើត
៨ ផ្សេងៗ (ក) ________________________________________________ $____________
(ខ) ________________________________________________ $____________

ហត្ថលេខារបស់អ្នកជំនួយការងារផ្ទះ ៖ ______________________ កាលបរិច្ឆេទ ៖ ______________
(ឈ្មោះ) ៖ ( )
ហត្ថលេខារបស់និយោជក ៖ ______________________________ កាលបរិច្ឆេទ ៖ ______________
(ឈ្មោះ) ៖ ( )
សាក្សី (ប្រសិនបើមាន) (ហត្ថលេខា) ៖ ____________________ កាលបរិច្ឆេទ ៖ ______________
(ឈ្មោះ) ៖ ( )

សម្គាល់ទី ១ ៖ សូមរកមើលជំពូកទី៨នៃ“សៀវភៅណែនាំដោយមានការអនុវត្តជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះដែលបានជ្រើសរើសពីបរទេស - អ្វីដែលអ្នកជំនួយការងារផ្ទះមកពីបរទេសនិងនិយោជករបស់ពួកគេគួរយល់ដឹង”សម្រាប់ព័ត៌មានទាក់ទងសិទ្ធិនិងកាតព្វកិច្ចរបស់និយោជក និងអ្នកជំនួយការងារផ្ទះមកពីបរទេស ។

សម្គាល់ទី ២ ៖ នេះគឺជាគំរូឯកសារសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ។ ភាគីដែលពាក់ព័ន្ធនឹងគំរូឯកសារនេះ គួរតែធានាថា ខ្លឹមសាររបស់ឯកសារនេះ គឺសមស្របសម្រាប់ការប្រើប្រាស់មុនពេលចាប់ផ្តើមចូលជាធរមាន ។ ភាគីទាំងនោះក៏ត្រូវបានរំឭកឲ្យស្នើសុំដំបូន្មានពីអ្នកជំនាញឯករាជ្យ នៅពេលដែលសមស្របផងដែរ ។

* សូមលុបចោលចំណុចដែលមិនសមស្រប

## សំណួរ

**បណ្ដាញទូរស័ព្ទសម្រាប់សាកសួរបន្ទាន់(បណ្ដាញនេះ គ្រប់គ្រងក្រោមខ្សែ"1823") ៖** 2717 1771

2157 9537 (ខ្សែទូរសព្ទបន្ទាន់ដែលបានផ្តល់សម្រាប់ស្ត្រីជំនួយការផ្ទះបរទេស)

**អាស័យដ្ឋានគេហទំព័រ ៖**

www.labour.gov.hk    www.fdh.labour.gov.hk

គណនីអ៊ីម៉ែលសសមាប់បញ្ហា នានាដែលទាក់ទងនឹងអ្នកបំរើការតាមផ្ទះ fdh-enquiry@labour.gov.hk

| សូមសាកសួរដោយផ្ទាល់ទៅកាន់ការិយាល័យនៃផ្នែកទំនាក់ទនងពលកម្ម | | |
|---|---|---|
| **Hong Kong** | Hong Kong East | 12/F, 14 Taikoo Wan Road, Taikoo Shing, Hong Kong |
| | Hong Kong West | 3/F, Western Magistracy Building, 2A Pokfulam Road, Hong Kong |
| **Kowloon** | Kowloon East | UGF, Trade and Industry Tower, 3 Concorde Road, Kowloon |
| | Kowloon South | 2/F, Mongkok Government Offices, 30 Luen Wan Street, Mongkok, Kowloon |
| | Kowloon West | Room 1009, 10/F, Cheung Sha Wan Government Offices, 303 Cheung Sha Wan Road, Sham Shui Po, Kowloon |
| | Kwun Tong | Units 801-806, 8/F, Tower 1, Millennium City 1, 388 Kwun Tong Road, Kwun Tong, Kowloon |
| **New Territories** | Tsuen Wan | 5/F, Tsuen Wan Government Offices, 38 Sai Lau Kok Road, Tsuen Wan, New Territories |
| | Kwai Chung | 6/F, Kwai Hing Government Offices, 166-174 Hing Fong Road, Kwai Chung, New Territories |
| | Tuen Mun | Unit 2, East Wing, 22/F, Tuen Mun Central Square, 22 Hoi Wing Road, Tuen Mun, New Territories |
| | Shatin & Tai Po | Rooms 304-313, 3/F, Sha Tin Government Offices, 1 Sheung Wo Che Road, Sha Tin, New Territories |

សសមាប់អាសយដ្ឋានការិយាល័យពាក់ព័ន្ធ ផ្ទផ្នែកទំនាក់ទំនងការងារ
សូមចូលេមីលេគហទំព័ររបស់ផ្នែកការងារ (https://www.labour.gov.hk/eng/tele/lr1.htm)។

Labour Department

01/2024